## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**សារណាបញ្ចប់ការសិក្សា**

# ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិ
# របស់ធនាគារអេស៊ីលីដា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ឡាយ ហុងលី**

សាស្ត្រាចារ្យណែនាំ

លោក **ឈាង ហ៊ុយ**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៣

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឡាយ ហុងលី** ជានិស្សិតថ្នាក់បរិញ្ញាបត្រមុខជំនាញ ធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី ១៣ ក្រុម B4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០២០ បានសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា** សូមគោរព និងសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ៖

- **លោកឪពុក និងអ្នកម្តាយ** ដែលលោកមានគុណទាំងទ្វេបានផ្តល់កំណើតដល់រូបខ្ញុំបាទ ហើយបានខិតខំប្រៀនប្រដៅអប់រំឲ្យខ្ញុំដើរលើគន្លងដែលមានភាពសមសួន និងទទួលបានការកោតសរសើរពីអ្នកផងទាំងពួង។ អរគុណលោកទាំងពីរដែលបានប្រឹងប្រែងធ្វើការរកស៊ីទាំងមេឃក្តៅ ភ្លៀង រលឹម ដើម្បីរកកម្រៃមកផ្គត់ផ្គង់លើចំណីអាហារ ការចាយវាយទូទៅ និងការសិក្សារបស់កូន។ លោកទាំងពីរបានធ្វើឲ្យកូនលោកទាំងពីរមានចំណេះដឹងគ្រប់គ្រាន់ក្នុងសង្គម សម្រាប់ជាដើមទុនក្នុងវិថីជីវិតមួយនេះ។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង ព្រមទាំងលោក និងលោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្កើតកម្មវិធីសិក្សាដែលមានគុណភាព ស្វះស្វែងបង្រៀនពីមុខជំនាញដោយយកចិត្តទុកដាក់ និងអប់រំផ្តល់ដំបូន្មានពីសង្គម ដល់រូបខ្ញុំ។ ការបណ្តុះបណ្តាលទាំងអស់នេះធ្វើឲ្យខ្ញុំក្លាយជាធនធានមនុស្សដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមជាតិ។
- **លោកសាស្ត្រាចារ្យ ឈាង ហ៊ុយ** ដែលលោកជាសាស្ត្រាចារ្យណែនាំក្នុងការស្រាវជ្រាវ និងការសរសេរសារណានេះ។ សូមអរគុណលោកគ្រូដែលបាន ជួយជ្រែមជ្រែង ចង្អុលបង្ហាញអំពីនីតិវិធីនានាក្នុងការស្រាវជ្រាវ។ លើសពីនេះទៀតលោកគ្រូក៏បានជួយកែតម្រូវផ្នែកជាច្រើនក្នុងសារណាដើម្បីធ្វើឲ្យស្នាដៃមួយនេះមានភាពល្អប្រសើរ។ បើគ្មានរូបលោកគ្រូទេ ការសិក្សាស្រាវជ្រាវ មួយនេះប្រាកដជាមិនអាចទៅរួចនោះទេ។
- **ក្រុមការងាររបស់ធនាគារអេស៊ីលីដា ផ្សារមូលបត្រកម្ពុជា និងគណៈកម្មាធិការមូលបត្រកម្ពុជា** ដែលបានខិតខំចេញផ្សាយនូវព័ត៌មាន និងទិន្នន័យសំខាន់ៗយ៉ាងច្រើន នៅលើគេហទំព័ររបស់ខ្លួន។ ព័ត៌មានទាំងអស់នេះជាគ្រឹះដ៏សំខាន់សម្រាប់សារណាមួយនេះ។
- **រៀមច្បងគ្រប់ជំនាន់** ដែលបានបន្សល់ស្នាដៃមានប្រយោជន៍ផ្សេងជាច្រើនសម្រាប់ខ្ញុំធ្វើការស្រាវ-ជ្រាវ។ ស្នាដៃទាំងអស់នេះបានផ្តល់ព័ត៌មាន និងគំរូជាច្រើនដល់រូបខ្ញុំ។
- និង **មិត្តរួមថ្នាក់** ដែលបានផ្តល់កម្លាំងចិត្តដល់រូបខ្ញុំដើម្បីបញ្ចប់ការសរសេរសារណាមួយនេះ។

ជាចុងក្រោយនេះ ខ្ញុំសូមជូនពរឲ្យលោកទាំងអស់ដែលបានរៀបរាប់ខាងលើជួបប្រទះតែសេចក្ដីសុខ ក្នុងជីវិត និងក្នុងការងារអាជីព ព្រមទាំងទទួលបានពុទ្ធិពរទាំងបួនប្រការពោលគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ទីផ្សារមូលបត្រកម្ពុជា មានដំណើរការជិតមួយទសវត្សមកហើយចាប់តាំងពីការសម្ពោធទីផ្សារមួយនេះឡើងនៅឆ្នាំ ២០១២។ បើទោះបីជាយ៉ាងនេះក្តីគេសង្កេតឃើញថាមជ្ឈដ្ឋានសាធារណជនទូទៅមិនសូវមានចំណាប់អារម្មណ៍ទៅលើវិស័យមូលបត្រនេះប៉ុន្មាននោះទេ។ ប៉ុន្តែនៅពេលដែលធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា បានប្រកាសថាខ្លួនមានបំណងក្នុងការចុះបញ្ជីជាមួយផ្សារមូលបត្រកម្ពុជា គេឃើញមានសារព័ត៌មាននានាក្នុងប្រទេសចុះផ្សាយអំពីដំណឹងមួយនេះយ៉ាងទូលំទូលាយ ហើយប្រជាពលរដ្ឋក្នុងបណ្តាញសង្គមក៏បានចែករំលែកព័ត៌មានជាច្រើនកុះករផងដែរ។

ដោយបានឃើញអំពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្លាបែបនេះ ធ្វើឲ្យខ្ញុំបាទដែលជានិស្សិតឆ្នាំទីបួនមុខជំនាញ ធនាគារ និងហិរញ្ញវត្ថុជំនាន់ទី ១៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានបំណងសរសេរអំពីដំណើរការឈានជើងចូលរបស់ធនាគារ អេស៊ីលីដា ទៅក្នុងផ្សារមូលបត្រកម្ពុជា ដើម្បីធ្វើជាសារណាបញ្ចប់ឆ្នាំសិក្សា និងចងក្រងជាឯកសារសម្រាប់សិស្សនិស្សិត និងសាធារណជនទូទៅធ្វើការស្វែងយល់។ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថាឯកសារមួយនេះនឹងមានសារប្រយោជន៍ដល់អ្នកស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាក្លាយជាផ្នែកមួយដ៏សំខាន់ ក្នុងការជម្រុញឲ្យមានការចាប់អារម្មណ៍លើការជួញដូរមូលបត្រក្នុងប្រទេសកម្ពុជាពីសំណាក់មហាជនផងដែរ។

ជាចុងក្រោយនេះ ខ្ញុំសូមអភ័យទោសទុកជាមុនប្រសិនបើឯកសារមួយនេះកំហុសឆ្គងណាមួយដែលទាក់ទងនឹងអក្ខរាវិរុទ្ធ ឬទិន្នន័យនានា។ ខ្ញុំបាទ បានខិតខំប្រឹងប្រែងពិនិត្យយ៉ាងម៉ត់ចត់ទៅការសរសេររួចមកហើយ ប៉ុន្តែឱកាសនៃកំហុសឆ្គងដោយអចេតនានៅតែមិនអាចជៀសផុតបាន។ ដូច្នេះខ្ញុំបាទទន្ទឹងរង់ចាំនឹងទទួលនូវការបញ្ចេញមតិក្នុងចេតនាចង់កែលម្អសារណារបស់ខ្ញុំមួយនេះឲ្យមានភាពល្អប្រសើរ ពីសំណាក់សិស្សនិស្សិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងមហាជនទូទៅ។

# មាតិកា

តារាងសម្គាល់អក្សរកាត់ .......... v

បញ្ជីតារាង .......... vi

បញ្ជីរូបភាព .......... vii

បញ្ជីឧបសម្ព័ន្ធ .......... viii

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ .......... ១

២. ចំណោទបញ្ហា .......... ២

៣. គោលបំណងនៃការស្រាវជាវ .......... ២

៤. ទំហំនិងដែនកំណត់របស់ការស្រាវជ្រាវ .......... ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ .......... ៣

ក. ប្រភពទិន្នន័យ .......... ៣

ខ. ការវិភាគ .......... ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ .......... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ៤

## ជំពូកទី១៖ រំលឹកទ្រឹស្តី

១.១. ទីផ្សារមូលបត្រ .......... ៥

១.១.១. និយមន័យ .......... ៥

១.១.២. អត្ថប្រយោជន៍របស់ទីផ្សារមូលបត្រ .......... ៥

១.២. មុខងារទីផ្សារមូលបត្រ .......... ៦

១.២.១. ការបង្កើតដើមទុន .......... ៦

១.២.២. សន្ទនីយភាព .......... ៦

១.៣. ប្រភេទមូលបត្រ .......... ៦

១.៣.១. មូលបត្រកម្មសិទ្ធ "ភាគហ៊ុន" .......... ៦

១.៣.២. មូលបត្របំណុល "សញ្ញាបណ្ណ" .......... ៧

១.៤. ប្រភេទទីផ្សារមូលបត្រ .......... ៩

១.៤.១. ទីផ្សារមូលធន (Capital Market) .......... ៩

១.៤.២. ទីផ្សាររូបិយវត្ថុ (Money Market) ........ ៩
១.៤.៣. ទីផ្សារដំបូង (Primary Market) ........ ១០
១.៤.៤. ទីផ្សារបន្ទាប់ (Secondary Market) ........ ១០
១.៤.៥. ទីផ្សារមូលបត្រមានការរៀបចំ (Organized Securities Market) ........ ១១
១.៤.៦. ទីផ្សាររំលងបញ្ជរ (Over-the-Counter Market) ........ ១១
១.៥. ស្ថាប័នសំខាន់ៗ និងស្ថាប័នបន្ទាប់បន្សំក្នុងទីផ្សារមូលបត្រនៃប្រទេសកម្ពុជា ........ ១១
១.៥.១. គណៈកម្មការមូលបត្រមូលបត្រកម្ពុជា (គ.ម.ក.) ........ ១២
១.៥.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ........ ១២
១.៥.៣. ក្រុមហ៊ុនមូលបត្រ ........ ១២
១.៥.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រ ........ ១៣
១.៥.៥. ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ........ ១៤
១.៥.៦. ក្រុមហ៊ុនផ្តល់សេវាបកប្រែ ........ ១៦
១.៥.៧. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ........ ១៦
១.៥.៨. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ........ ១៨
១.៥.៩. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ........ ១៨
១.៥.១០. បញ្ជីឈ្មោះភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ........ ១៨
១.៥.១១. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ........ ១៩
១.៦. យន្តការចូលទីផ្សារមូលបត្រជាសាធារណៈ ........ ១៩

## ជំពូកទី២៖ ទិដ្ឋភាពទូទៅរបស់ធនាគារអេស៊ីលីដា

២.១. ប្រវត្តិសង្ខេបអេស៊ីលីដា និងប្រវត្តិការបង្កើតសាខារបស់ធនាគារអេស៊ីលីដា ........ ២៣
២.១.១. ប្រវត្តិសង្ខេបអេស៊ីលីដា ........ ២៣
២.១.២. ប្រវត្តិការបង្កើតសាខារបស់ធនាគារអេស៊ីលីដា ........ ២៥
២.២. រូបសញ្ញា និងអត្ថន័យរបស់ធនាគារអេស៊ីលីដា ........ ២៦
២.២.១. រូបសញ្ញាបច្ចុប្បន្ន របស់ធនាគារអេស៊ីលីដា ........ ២៦
២.២.២. អត្ថន័យ របស់ធនាគារអេស៊ីលីដា ........ ២៦
២.២.៣. រូបសញ្ញាពីអតីតកាល របស់ធនាគារអេស៊ីលីដា ........ ២៧
២.៣. រូបសញ្ញាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ ធនាគារអេស៊ីលីដា ........ ២៧

២.៤. ទស្សនៈ និងបេសកកម្ម ........................................................................................................ ២៨
២.៤.១. ទស្សនៈ ........................................................................................................ ២៨
២.៤.២. បេសកកម្ម ........................................................................................................ ២៨
២.៥. ក្រុមប្រឹក្សាភិបាល ........................................................................................................ ២៨
២.៦. គណៈកម្មាធិការប្រតិបត្តិ ........................................................................................................ ២៨
២.៧. សេវាកម្ម និងផលិតផល ........................................................................................................ ២៩
២.៧.១. សេវាធនាគារអេឡិចត្រូនិច ........................................................................................................ ២៩
២.៧.២. សេវាឥណទាន ........................................................................................................ ៣១
២.៧.៣. សេវាបញ្ញើ - សន្សំ ........................................................................................................ ៣២
២.៧.៤. សេវាផ្ទេរប្រាក់ ........................................................................................................ ៣២
២.៧.៥. សេវាចាត់ចែងសាច់ប្រាក់ ........................................................................................................ ៣៣
២.៧.៦. សេវាផ្សេងៗទៀត ........................................................................................................ ៣៤

**ជំពូកទី៣៖ ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា**

៣.១. ព័ត៌មានក្រុមហ៊ុនពាក់ព័ន្ធនឹងការបោះផ្សាយ IPO ........................................................................................................ ៣៥
៣.២. ការបង្ហាញព័ត៌មានហិរញ្ញវត្ថុរបស់ធនាគារ ........................................................................................................ ៣៩
៣.៣. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិចេញផ្សាយដំបូង (IPO) ........................................................................................................ ៤៤
៣.៣.១. ព័ត៌មានអំពីការដាក់សំណើការផ្សាយលក់មូលបត្រកម្មសិទ្ធិ ........................................................................................................ ៤៤
៣.៣.២. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ ........................................................................................................ ៤៥
៣.៣.៣. តម្លៃមួយឯកតានៃមូលបត្រកម្មសិទ្ធិ ........................................................................................................ ៤៥
៣.៣.៤. សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រ ........................................................................................................ ៤៦
៣.៤. សិទ្ធិរបស់ភាហ៊ុនិក ........................................................................................................ ៤៦
៣.៥. គោលនយោបាយភាគលាភ ........................................................................................................ ៥០
៣.៦. ដំណើរការធ្វើប៊ុកបៀលឌីង ........................................................................................................ ៥២
៣.៦.១. ការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិ ........................................................................................................ ៥២
៣.៦.២. ការបង្ហាញព័ត៌មានលម្អិត ........................................................................................................ ៥២
៣.៦.៣. ការបរិច្ឆេទប៊ុកបៀលឌីង ទីតាំង និងនីតិវិធី ........................................................................................................ ៥៣
៣.៦.៤. លទ្ធផលនៃការធ្វើប៊ុកបៀលឌីង ........................................................................................................ ៥៤

៣.៧. ដំណើរការធ្វើបរិវិសកម្ម ........................................................................................... ៥៥
៣.៨. ឥទ្ធិពលភាគហ៊ុនអេស៊ីលីដាក្នុងផ្សារមូលបត្រកម្ពុជា ........................................................ ៥៦
៣.៨.១. ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅ ផ.ម.ក. ........................................ ៥៦
៣.៨.២. ការជួញដូរមូលបត្រកម្មសិទ្ធិ ABC នៅ ផ.ម.ក. ........................................................ ៥៧

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................................................................................ ៦១
២. អនុសាសន៍ .................................................................................................................. ៦២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

| អក្សរកាត់ | អក្សរពេញ |
|---|---|
| គ.ម.ក. | គណៈកម្មការមូលបត្រកម្ពុជា |
| ផ.ម.ក. | ផ្សារមូលបត្រកម្ពុជា |
| ម.ក. | ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត |
| ឯ.ក | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| IPO | Initial Public Offering |
| SECC | Securities and Exchange Commission of Cambodia |
| CSX | Cambodia Securities Exchange |

# បញ្ជីតារាង

តារាងទី១៖ ប្រវត្តិសង្ខេបនៃការវិវត្តន៍របស់ធនាគារអេស៊ីលីដា ........................................................... ២៤
តារាងទី២៖ ប្រវិត្តការបង្កើតសាខារបស់ធនាគារ អេស៊ីលីដា ............................................................. ២៥
តារាងទី៣៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនបោះផ្សាយមូលបត្រ .............................................................. ៣៧
តារាងទី៤៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនធានាទិញមូលបត្រ ................................................................ ៣៧
តារាងទី៥៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ............................................................. ៣៨
តារាងទី៦៖ ព័តមានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាផ្នែកសវនកម្ម ........................................................... ៣៩
តារាងទី៧៖ តារាងតុល្យការរួមរបស់ធនាគារអេស៊ីលីដា ................................................................... ៣៩
តារាងទី៨៖ របាយការណ៍លទ្ធផលរួមរបស់ធនាគារអេស៊ីលីដា ........................................................... ៤២
តារាងទី៩៖ លក្ខខណ្ឌនៃសំណើលក់មូលបត្រ ..................................................................................... ៤៤
តារាងទី១០៖ ផែនការបែងចែកមូលបត្រ ........................................................................................... ៤៥
តារាងទី១១៖ ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅផ.ម.ក. ............................................. ៥៦
តារាងទី១២៖ ទិន្នន័យការជួញដូរ ABC សប្តាហ៍ទី១ ......................................................................... ៥៧
តារាងទី១៣៖ ទិន្នន័យការជួញដូរ ABC សប្តាហ៍ទី២ ......................................................................... ៥៨
តារាងទី១៤៖ ទិន្នន័យការជួញដូរ ABC សប្តាហ៍ទី៣ ......................................................................... ៥៩
តារាងទី១៥៖ ទិន្នន័យការជួញដូរ ABC សប្តាហ៍ទី៤ ......................................................................... ៥៩

# បញ្ជីរូបភាព

រូបភាពទី១៖ រូបសញ្ញាបច្ចុប្បន្នធនាគារអេស៊ីលីដា ..... ២៦
រូបភាពទី២៖ រូបសញ្ញាធនាគារអេស៊ីលីដាពីអតីតកាល ..... ២៧
រូបភាពទី៣៖ រូបសញ្ញាធនាគារអេស៊ីលីដា រួមនិងរូបសញ្ញារបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ..... ២៧
រូបភាពទី៤៖ ក្រុមប្រឹក្សាភិបាលធនាគារអេស៊ីលីដា ..... ២៨
រូបភាពទី៥៖ គណៈកម្មាធិការប្រតិបត្តិធនាគារអេស៊ីលីដា ..... ២៩

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ពាក្យស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ

ឧបសម្ព័ន្ធទី២៖ ពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីង

ឧបសម្ព័ន្ធទី៣៖ ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

ឧបសម្ព័ន្ធទី៤៖ បញ្ជីវិនិយោគិនទទួលបានជោគជ័យ និងចំនួនភាគហ៊ុនដែលបានបែងចែក

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ពីមួយឆ្នាំទៅមួយឆ្នាំ វិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាក់ស្តែងជាប្រវិត្តសាស្ត្រនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ប្រទេសកម្ពុជាបានធ្វើពិធីសម្ពោធដាក់ឱ្យដំណើរការក្រុម-ហ៊ុនផ្សារមូលបត្រកម្ពុជាជាផ្លូវការ។ ទីផ្សារមូលបត្រគឺជាកន្លែងសម្រាប់ធ្វើការជួញដូរ មូលបត្រកម្មសិទ្ធិ មូល-បត្របំណុល និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ ទីផ្សារមូលបត្រនេះគឺជាកត្តាមូលដ្ឋានមួយដែលមានសារសំខាន់ជាទីបំផុតព្រោះវាជាមធ្យោបាយមួយដែលក្រុមហ៊ុនអាចទទួលបានមូលធនបន្ថែមសម្រាប់ធ្វើការពង្រីកអាជីវកម្ម ពីសំណាក់អ្នកវិនិយោគដែលសម្លឹងឃើញពីផលប្រយោជន៍ក្នុងការវិនិយោគជាមួយក្រុមហ៊ុន។

យ៉ាងណាក៏ដោយ បើទោះបីជាទីផ្សារមូលបត្រនេះមានអាយុកាលជិតមួយទសវត្សហើយក្តី គេសង្កេតឃើញថាមានចំនួនក្រុមហ៊ុនតែប្រាំមួយប៉ុណ្ណោះដែលបានចុះបញ្ជីនៅផ្សារកម្មសិទ្ធ។ ក្រុមហ៊ុនទាំងនោះរួមមាន (១)*រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (២)ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (៣)កំពង់ផែស្វយ័តភ្នំពេញ (៤)តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (៥)កំពង់ផែស្វយ័តក្រុងព្រះសីហនុ* និង *(៦)ធនាគារ អេស៊ីលីដា ភីអិលស៊ី*[1]។ គួរបញ្ជាក់ផងដែរថាធនាគារ អេស៊ីសីដាជាស្ថាបន័ហិរញ្ញវត្ថុដំបូងគេបង្អស់ដែលបានចុះបញ្ជីជាក្រុមហ៊ុនសាជីវកម្មជាមួយផ្សារមូលបត្រកម្ពុជា។

មុនពេលការឈានជើងចូលផ្សារមូលបត្រកម្ពុជារបស់ធនាគារ អេស៊ីលីដា គេសង្កេតឃើញថាចលនាមូលធននៅក្នុងផ្សារមូលបត្រកម្ពុជាមានចំនួនតែ ២% ប៉ុណ្ណោះបើធៀបជាមួយនឹងផលិតផលក្នុងស្រុកសរុប (GDP) ពោលគឺកម្ពុជាឈរនៅលំដាប់ថ្នាក់ទី៩នៅក្នុងតំបន់អាស៊ាន។ ការប្រកាសការចុះបញ្ជីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី បានធ្វើអោយសេដ្ឋកិច្ចវិទូក្នុងប្រទេសកម្ពុជាបង្ហាញការសារទរ និងមានសុទិដ្ឋិនិយមយ៉ាងខ្លាំងក្លា ព្រោះគេរំពឹងថាការដោះដូរមូលបត្ររបស់ស្ថាបន័មួយនេះនឹងធ្វើអោយចលនាមូលធននៅក្នុងទីផ្សារមូលបត្រកម្ពុជាមានការកើនឡើង[2]។

ដោយសង្កេតឃើញពីសក្តានុពលរបស់ធនាគារ អេស៊ីលីដា នៅក្នុងទីផ្សារមូលបត្រ បានជាធ្វើឱ្យខ្ញុំ

1 ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, បញ្ជីឈ្មោះក្រុមហ៊ុន, http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលទស្សនាថ្ងៃទី ០១ មិថុនា ២០២០)

2 The Phnom Penh Post, Could CSX's low liquidity soon be history?, www.phnompenhpost.com (ចូលទស្សនាថ្ងៃទី ០១ មិថុនា ២០២០)

បាទ មានការចាត់អារម្មណ៍យ៉ាងខ្លាំង ហើយមានបំណងចង់ចងក្រងពីមូលបត្រកម្មសិទ្ធ របស់ស្ថាបន័មួយនេះឡើង។

## ២. ចំណោទបញ្ហា

តាមការសង្កេត បើទោះបីជាកម្ពុជាមានទីផ្សារមូលបត្រជិតដប់ឆ្នាំក៏ដោយ ក៏ការយល់ដឹងអំពីមូលបត្ររបស់ប្រជាជនទូទៅនៅមានកម្រិតនៅឡើយ។ ហើយការជួញដូរមូលបត្រនៅទីផ្សារក៏មានភាពមិនទូលំទូលាយផងដែរ។ ប៉ុន្តែជារឿងគួរឱ្យភ្ញាក់ផ្អើលណាស់ដែលធនាគារអេស៊ីលីដា ដែលមានទ្រព្យសកម្មច្រើនជាងគេលំដាប់លេខពីរក្នុងចំណោមធនាគារក្នុងប្រទេសកម្ពុជា[3] សម្រេចចិត្តចូលទីផ្សារមូលបត្រ។ ដូច្នេះហើយនៅក្នុងការសិក្សាស្រាវជ្រាវនេះខ្ញុំនឹងផ្តោតសំខាន់ទៅលើបញ្ហាបីដូចខាងក្រោម៖

- តើធនាគារអេស៊ីលីដាត្រូវអនុវត្តដំណើរការអ្វីខ្លះដើម្បីអាចចុះបញ្ជីជាមួយផ្សារមូលបត្រកម្ពុជា?
- តើធនាគារអេស៊ីលីដា មានយុទ្ធសាស្ត្រអ្វីខ្លះដែលអាចទាក់ទាញអ្នកវិនិយោគ ឲ្យធ្វើការវិនិយោគជាមួយមូលបត្រកម្មសិទ្ធិរបស់ខ្លួន?
- តើមូលបត្ររបស់ធនាគារនេះ នឹងមានឥទ្ធិពលអ្វីខ្លះដល់ទីផ្សារមូលបត្រនៃប្រទេសកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការធ្វើការស្រាវជ្រាវលើប្រធានបទ **ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា** នេះមានគោលបំណង ដូចខាងក្រោម៖

- សិក្សាអំពីដំណើរការដែលធនាគារអេស៊ីលីដាត្រូវអនុវត្តដើម្បីអាចចុះបញ្ជីជាមួយនឹង ផ្សារមូលបត្រកម្ពុជា។
- ស្វែងយល់អំពីយុទ្ធសាស្ត្រដែលធនាគារអេស៊ីលីដា ប្រើប្រាស់ដើម្បីទាក់ទាញអ្នកវិនិយោគឱ្យធ្វើការវិនិយោគជាមួយមូលបត្ររបស់ខ្លួន។
- សិក្សាអំពីឥទ្ធិពលនៃមូលបត្រកម្មសិទ្ធរបស់ធនាគារអេស៊ីលីដានៅក្នុងផ្សារមូលបត្រកម្ពុជា។

## ៤. ទំហំនិងដែនកំណត់របស់ការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ ផ្តោតសំខាន់ទៅលើដំណើរការបោះផ្សាយមូលបត្រសាធារណៈលើកដំបូង (IPO) និងឥទ្ធិពលរបស់មូលបត្រកម្មសិទ្ធរបស់ធនាគារអេស៊ីលីដានៅក្នុងទីផ្សារមូលបត្រកម្ពុជា។ ឥទ្ធិ-ពលរបស់ភាគហ៊ុនអេស៊ីលីដានឹងត្រូវបង្ហាញតាមការរយៈទំហំការជួញដូររបស់វា ក្នុងផ្សារមូលបត្រចាប់ពីថ្ងៃ

3 ធនាគារអេស៊ីលីដា, របាយការណ៍ប្រចាំឆ្នាំ២០១៩, https://www.acledabank.com.kh/kh/assets/pdf_zip/ACLEDA_AnnRept2019_large_kh.zip, (ចូលទស្សនាថ្ងៃទី ០១ មិថុនា ២០២០)

ចេញផ្សាយ IPO នៅថ្ងៃទី២៥ ឧសភា ២០២០ ដល់ ថ្ងៃទី១៩ មិថុនា ២០២០ ពោលគឺមានរយៈពេលបួនសប្តាហ៍។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ពឹងផ្អែកលើប្រភពទិន្នន័យ និងការវិភាគដូចខាងក្រោម៖

### ក. ប្រភពទិន្នន័យ

ទិន្នន័យដែលត្រូវបានយកមកសិក្សាក្នុងសារណាមួយនេះជាប្រភេទទិន្នន័យមានស្រាប់ (បន្ទាប់បន្សំ) ដែលក្នុងនោះរួមមាន៖

- ច្បាប់ អនុក្រឹត្យ និងប្រកាស នានាដែលពាក់ព័ន្ធនឹងការចុះបញ្ជីនៃធនាគារអេស៊ីលីដាក្នុងផ្សារមូលបត្រកម្ពុជា។
- ពត៌មានអំពីមូលបត្រកម្មសិទ្ធិក្នុងគេហទំព័ររបស់ធនាគារអេស៊ីលីដា។
- ពត៌មានជាតួលេខពាក់ព័ន្ធនឹងភាគហ៊ុនក្នុងគេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា។
- ពត៌មានអំពីច្បាប់ ប្រកាស យន្តការ និងគោលការណ៍ណែនាំនានាដែលពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រក្នុងគេហទំព័ររបស់គណៈកម្មាធិការ។
- ទិន្នន័យផ្សេងៗបានពីសារពត៌មានក្នុងស្រុក និងបរទេស។

### ខ. ការវិភាគ

អ្នកនិពន្ធប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យដើម្បីធ្វើការវិភាគទិន្នន័យ និងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការតាក់តែងសារណានេះ ធ្វើឡើងក្នុងគោលបំណងដើម្បីបង្កើតស្នាដៃថ្មី និងពុទ្ធិចំណេះដឹងដែលបម្រើដល់សង្គមជាតិកម្ពុជា។ ខ្ញុំសង្ឃឹមថាសារណានេះនឹងធ្វើឱ្យ៖

- **ខ្លួនឯងផ្ទាល់**
  - យល់ដឹងច្បាស់អំពីប្រវិត្តសាវតារបស់ទីផ្សារមូលបត្រកម្ពុជា។
  - មានចំណេះដឹងកាន់តែជ្រៅជ្រះក្នុងការប្រតិបត្តិការទិញលក់មូលបត្រ។
  - ស្វែងយល់អំពីដំណើរការក្នុងការចុះបញ្ជីជាមួយទីផ្សារមូលបត្រកម្ពុជា។
  - ពង្រីកចំណេះដឹងក្នុងសរសេរកិច្ចការស្រាវជ្រាវ ការវិភាគទិន្នន័យ និងការស្វែងរកពត៌មាន។
- **សិស្ស និស្សិត និងអ្នកស្រាវជ្រាវ**

- សិក្សាស្វែងយល់ពីទីផ្សារមូលបត្រកម្ពុជា និងដំណើរប្រតិបត្តិការទិញលក់មូលបត្រ។
- ជាប្រភពទុននៃចំណេះដឹងពីមូលបត្រកម្មសិទ្ធរបស់ធនាគារអេស៊ីលីដា។
- សិក្សាពីពាក្យគន្លឹះមួយចំនួនទាក់ទងនឹងទីផ្សារមូលបត្រ ដែលមាននៅក្នុងមេរៀនហិរញ្ញវត្ថុ។

➢ **គណៈគ្រប់គ្រងធនាគារអេស៊ីលីដា**

- ផ្តល់ជាឯកសារសម្រាប់អ្នកវិនិយោគរបស់ធនាគារអេស៊ីលីដា។
- ជាប្រភពព័ត៌មានដែលមានប្រយោជន៍សម្រាប់គណៈគ្រប់គ្រង សំលឹងមើលពីបញ្ហានានា ហើយដោះស្រាយយ៉ាងសមស្រប។

➢ **មជ្ឈដ្ឋានទូទៅ**

- ផ្តល់ព័ត៌មានសម្រាប់អ្នកដែលមានបំណង ចង់វិនិយោគជាមួយមូលបត្រកម្មសិទ្ធរបស់ធនាគារអេស៊ីលីដា។
- ផ្តល់ការយល់ដឹងអំពីឥទ្ធិពលរបស់មូលបត្រកម្មសិទ្ធនៃធនាគារអេស៊ីលីដា ទៅលើផ្សារមូល-បត្រកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីបង្កភាពងាយស្រួលដល់អ្នកអាន និងអ្នកស្រាវជ្រាវ សារណាក្រោមប្រធានបទ **ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា** នេះត្រូវបានបែងចែកជា ៤ ជំពូក។



# ជំពូកទី១៖
# រំលឹកទ្រឹស្តី

# ជំពូកទី១៖ រំលឹកទ្រឹស្តី

## ១.១. ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាកម្លាំងចលករក្នុងការអភិវឌ្ឍខឿនសេដ្ឋកិច្ចប្រទេសជាតិដោយសារតែវាធ្វើឲ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់មូលនិធិ តាមរយៈការធ្វើឲ្យមានលំហូរនៃសាច់ប្រាក់ពីអ្នកមានមូលធនតែពុំមាននូវឱកាសវិនិយោគទៅដល់បុគ្គល ឬនីតិបុគ្គលដែលមានឱកាសវិនិយោគតែខ្វះមូលធន។ ក្នុងបែបន័យនេះ ទីផ្សារមូលបត្រពិតជាមានសារៈសំខាន់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចប្រទេសជាតិណាដែលមានផ្សារមូលបត្រ ហើយមានដំណើរការបានល្អ។

### ១.១.១. និយមន័យ

ច្បាប់ស្តីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ឲ្យនិយមន័យដល់ទីផ្សារមូលបត្រថា គឺជាទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្នើការទិញ-លក់មូលបត្រ[4]។

### ១.១.២. អត្ថប្រយោជន៍របស់ទីផ្សារមូលបត្រ

ចទីផ្សារមូលបត្រ គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចប្រទេសជាតិ ដែលវាមានប្រយោជន៍ដូចជា៖

- ជម្រុញឱ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើ-ប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច។
- ជាមធ្យោបាយមួយប្រមែប្រមូលកៀរគរ នូវប្រភពមូលធនដែលនៅទំនេរតូចៗមិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងសេដ្ឋកិច្ចរូបវន្ត។
- ជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។
- ជាឧបករណ៍មួយដើម្បីទាក់ទាញមូលធនពីបរទេស។
- ជម្រុញឱ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធភាព និងតម្លាភាព។
- ជួយជម្រុញឱ្យមានប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។
- ជួយបង្កើតនូវទម្លាប់នៃការវិនិយោគ[5]។

---

4 ច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/០១០៧/០២៨, ២៣ តុលា ២០០៧, សន្ធានក្រម

## ១.២. មុខងារទីផ្សារមូលបត្រ

ទីផ្សារមូលបត្រមានមុខងារតួនាទីពីរសំខាន់ ពោលគឺៈ

### ១.២.១. ការបង្កើតដើមទុន

ទីផ្សារមូលបត្រ ជាកន្លែងប្រជុំវិនិយោគិនទាំងអស់ដែលមានទុន ដើម្បីវិនិយោគទៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងឡាយណាដែលស្វែងរកទុនដើម្បីបង្កើនមូលធន។

### ១.២.២. សន្ទនីយភាព

សន្ទនីយភាពជាលទ្ធភាពក្នុងការលក់ឧបករណ៍វិនិយោគនៅក្នុងទីផ្សារមូលបត្រ។ ទីផ្សារមូលបត្រផ្តល់សន្ទនីយភាពតាមរយៈការផ្តល់ជាទីកន្លែងជួញដូរដែលក្នុងនោះអ្នកទិញ និងអ្នកលក់ជួបគ្នាដើម្បីធ្វើការព្រមព្រៀងតម្លៃ និងធ្វើការជួញដូរមូលបត្រ។ សកម្មភាពនេះផ្តល់សន្ទនីយភាពក្នុងការទិញ និងលក់មូលបត្រនៅក្នុងទីផ្សារមូលបត្រ[6]។

## ១.៣. ប្រភេទមូលបត្រ

មានមូលបត្រច្រើនប្រភេទណាស់ ដែលត្រូវបានគេជួញដូរក្នុងទីផ្សារមូលបត្រនានា នៅលើពិភពលោក ប៉ុន្តែយើងអាចបែងចែកមូលបត្រជាពីរប្រភេទធំៗ ពោលគឺៈ

(១) មូលបត្រកម្មសិទ្ធ ឬ "ភាគហ៊ុន" និង

(២) មូលបត្របំណុល ឬ "សញ្ញាបណ្ណ"។

### ១.៣.១. មូលបត្រកម្មសិទ្ធ "ភាគហ៊ុន"

មូលបត្រកម្មសិទ្ធ ឬភាគហ៊ុនតំណាងឱ្យភាពជាម្ចាស់នៃក្រុមហ៊ុន។ វិនិយោគិនអាចទទួលបានផលចំណេញពីភាគហ៊ុនតាមវិធីពីរយ៉ាងពោលគឺ (១)តាមរយៈការលក់ចេញពេលហ៊ុនឡើងថ្លៃ ឬ(២) តាមរយៈការទទួលបានភាគលាភ។

ការវិនិយោគលើភាគហ៊ុន មានហានិភ័យជាងការវិនិយោគលើសញ្ញាបណ្ណពីព្រោះថាអ្នកកាន់ភាគហ៊ុនមានអទិភាពទាបជាងអ្នកកាន់សញ្ញាបណ្ណនៅពេលក្រុមហ៊ុនមានបញ្ហា ហើយភាគហ៊ុនអាចផ្លាស់ប្តូរអាស្រ័យតាមប្រាក់ចំណេញរបស់ក្រុមហ៊ុន។ បើទោះបីយ៉ាងនេះក្តីការវិនិយោគជាមួយភាគហ៊ុនអាចនឹងមានផលចំណេញច្រើនជាងសញ្ញាបណ្ណ។

---

5 គណៈកម្មាធិការមូលបត្រកម្ពុជា, ពុទ្ធិមូលបត្រ-សំណួរចម្លើយបច្ចេកទេស, http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី ០៩ មិថុនា ២០២០)

6 បៀន សាំង, ២០១១, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ, ទំព័រ ៨

ភាពខុសគ្នាមួយរវាងភាគហ៊ុន និងសញ្ញាបណ្ណគឺ ភាគហ៊ុនពុំមានអាយុកាលកំណត់ដូចសញ្ញាបណ្ណឡើយ។ អ្នកកាន់ភាគហ៊ុនមានសិទ្ធក្នុងការបោះឆ្នោតនានាក្នុងក្រុមហ៊ុន ចំណែកឯអ្នកកាន់សញ្ញាបណ្ណពុំមានសិទ្ធនេះនោះទេ[7]។

ជាទូទៅមូលបត្រកម្មសិទ្ធមានពីរប្រភេទធំៗ៖

- **ភាគហ៊ុនមានសិទ្ធិបោះឆ្នោត (Common Stock)**៖ ក្រុមហ៊ុនសាជីវកម្មទាំងអស់ អាចធ្វើការបោះផ្សាយភាគហ៊ុនមួយដែលមានសិទ្ធិទទួលការទូទាត់ភាគលាភ ឬកម្រៃផ្សេងៗចុងក្រោយគេនៅលើទ្រព្យសកម្មរបស់ក្រុមហ៊ុនសាជីវកម្មដែលបោះផ្សាយប្រភេទនេះក្នុងករណីក្ស័យធន។ ដូច្នេះមានន័យថា អ្នកកាន់កាប់មូលបត្រផ្សេងៗរបស់ក្រុមហ៊ុនដូចជាសញ្ញាបណ្ណ និង ភាគហ៊ុនបុរិមា (Preferred Stock) នឹងទទួលបានការទូទាត់សំណងមុនអ្នកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត។
- **ភាគហ៊ុនបុរិមា (Preferred Stock)**៖ ភាគហ៊ុននេះជាទូទៅមិនមានសិទ្ធបោះឆ្នោតនៅក្នុងក្រុមហ៊ុនទេ។ ពាក្យថា"បុរិមា" (Preferred) គឺសង្កត់ន័យថាភាគហ៊ុននេះមានសិទ្ធិទទួលបានការបែងចែងភាគលាភ ឬក៏ទាមទារសិទ្ធិទទួលផលលើទ្រព្យសកម្មទាំងឡាយរបស់ក្រុមហ៊ុនពេលមានបញ្ហាក្ស័យធន មុនពេលទូទាត់ទៅទៅភាគហ៊ុនិកនៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត ប៉ុន្តែក្រោយអ្នកដែលកាន់មូលបត្របំណុល។ ភាគហ៊ុនបុរិមាអាចត្រូវបានបោះផ្សាយក្នុងទម្រង់មួយដែលគេស្គាល់ថាជាភាគហ៊ុនបុរិមាអាចប្តូរបាន (Convertible Preferred Stock)។ ក្នុងន័យនេះ ភាគហ៊ុនបុរិមាអាចត្រូវបានប្តូរទៅជា ភាគហ៊ុនមានសិទ្ធិបោះឆ្នោតបាន[8]។

**១.៣.២. មូលបត្របំណុល "សញ្ញាបណ្ណ"**

មូលបត្រប្រភេទនេះត្រូវបានគេជួញដូរជាទម្រង់ឧបករណ៍បំណុលដែលត្រូវបានបោះផ្សាយដោយរដ្ឋាភិ- បាល ភ្នាក់ងារនានានៃរដ្ឋាភិបាល និងក្រុមហ៊ុនសាជីវកម្ម។ សញ្ញាបត្រទាំងអស់គឺជាកម្ចីដែលផ្តល់ដោយអ្នកកាន់កាប់សញ្ញាបណ្ណ (អ្នកទិញ) ទៅឱ្យក្រុមហ៊ុនបោះផ្សាយថានឹងសងត្រលប់មកវិញនូវចំនួនដែលបានឱ្យខ្ចី (ប្រាក់ដើម) ទៅដល់អ្នកទិញសញ្ញាបណ្ណ រួមថែមជាមួយការប្រាក់ដែលបានព្រមព្រៀងនៅពេល ឬមុនពេលបោះផ្សាយសញ្ញាបណ្ណ។ ការប្រាក់អាចត្រូវបង់ជាដំណាក់កាលនៅក្នុងអំឡុងពេលនៃការឱ្យខ្ចី ឬអាចបង់សរុបរួមជាមួយប្រាក់ដើមនៅពេលដល់អាយុកាលត្រូវសង។

ហេតុដែលគេថាសញ្ញាបណ្ណជាឧបករណ៍បំណុល គឺដោយសារតែអ្នកកាន់សញ្ញាបណ្ណមិនមានសិទ្ធិអ្វី

7 Frederic S. Mishkin និង Stanley G. Eakins, ២០១១, Financial Markets and Institutions, ទំព័រ ៣០២-៣០៣

8 បៀន សាំង, ២០១១, មូលដ្ឋានគ្រឹះទីផ្សារមូលបត្រ, ទំព័រ ៣៥-៣៦

ទាំងអស់លើកម្មសិទ្ធិណាមួយរបស់ក្រុមហ៊ុន ហើយពួកគេក៏ពុំមានសិទ្ធិក្នុងការបោះឆ្នោតនានា ក្នុងក្រុមហ៊ុនដែរ។ ប៉ុន្តែអ្នកកាន់សញ្ញាបណ្ណមានអត្ថប្រយោជន៍មួយ ពោលគឺនៅពេលក្រុមហ៊ុនក្ស័យធនហើយត្រូវធ្វើជម្រះបញ្ជី (Liquidation) អ្នកកាន់សញ្ញាបណ្ណត្រូវបានទូទាត់សងមុនអ្នកកាន់ភាគហ៊ុន។

មូលបត្របំណុល ឬ សញ្ញាបណ្ណនេះត្រូវបានគេបែងចែកជាច្រើនប្រភេទដូចខាងក្រោម៖

- **សញ្ញាបណ្ណបំណុលទូទៅ និងសញ្ញាបណ្ណប្រាក់ចំណូល** (General Obligation and Revenue Bonds)៖ ជាទូទៅសំដៅលើសញ្ញាបណ្ណរបស់រដ្ឋាភិ- បាល។ វាទទួលបានភាពជឿជាក់ខ្ពស់ និងត្រូវបានធានាដោយអំណាចពន្ធ (ភ្នាក់ងាររបស់រដ្ឋអាចដំឡើងពន្ធដើម្បីមានចំណូលសងពេលដល់អាយុកាល)។ ភ្នាក់ងារដែលទទួលបានសិទ្ធិបោះផ្សាយសញ្ញាបណ្ណបំណុលនេះគឺមានតែភ្នាក់ងាររបស់ប្រទេសមួយ ឬសាលាក្រុងមួយ។ល។
- **សញ្ញាបណ្ណរតនាគារ ឬរដ្ឋាភិបាល** (Treasury Bonds)៖ នៅពេលមានតម្រូវការថវិកាជាតិដើម្បីធ្វើហិរញ្ញប្បទានរយៈពេលវែង រដ្ឋាភិបាលអាចចេញលក់ធ្វើការបោះផ្សាយមូលបត្របំណុលប្រភេទនេះដែលជាធម្មតាមានអាយុកាល ២០ ទៅ៣០ឆ្នាំ។ ជាទូទៅ សញ្ញាបណ្ណប្រភេទនេះមានជម្រើសមួយដែលអ្នកបោះផ្សាយអាចធ្វើការទូទាត់សងមុនការកំណត់បានក្រោយរយៈពេលព្រមព្រៀងគ្នាមួយ។
- **បណ្ណរតនាគារ** (Treasury Notes)៖ វាត្រូវបានគេហៅថាឧបករណ៍វិនិយោគរយៈពេលមធ្យមព្រោះថាជាទូទៅវាមានឥណប្រទិទានពី ២ទៅ១០ឆ្នាំ។ បណ្ណរតនាគារមិនអាចទិញត្រឡប់វិញមុនកាលបរិច្ឆេទដូចសញ្ញារតនាគារនោះទេ ហើយបណ្ណរតនាគារជាធម្មតាផ្តល់ការប្រាក់រយៈពេល៦ខែម្តង។
- **បណ្ណបំណុលរតនាគារ** (Treasury Bills)៖ ជាមូលបត្របណុលរយៈពេលខ្លី ដែលជាមធ្យមវាមានអាយុកាល ៣, ៦, ៩, ឬ១២ខែ។ T-Bills មិនមានការផ្តល់ជូនជាការប្រាក់ ឬ គូប៉ុនទេ ដោយសារវាមានអាយុការខ្លីពេក។ ជំនួសមកវិញគេដាក់លក់វានៅតម្លៃ Discount (តម្លៃក្រោមតម្លៃចារឹក) ហើយនៅពេលដល់អាយុកាលគេនឹងទទួលបានតម្លៃចារឹកវិញ។
- **សញ្ញាបណ្ណចែករំលែកប្រាក់ចំណេញ** (Participating Bonds)៖ សញ្ញាបណ្ណប្រភេទនេះ មិនត្រឹមតែផ្តល់អត្រាការប្រាក់ក្នុងកម្រិតថេរួយនេះទេ ប៉ុន្តែថែមទាំងមានការចែករំលែកប្រាក់ចំណេញផងដែរ។ អ្នកកាន់កាប់សញ្ញាបណ្ណនេះ មានសិទ្ធិចូលរួមជាមួយភាគហ៊ុនិកដ៏ទៃទៀតក្នុងការចែកប្រាក់ចំណេញរបស់សាជីវកម្មដែលទទួលបាននៅក្នុងទំហំមួយដូចមានចែងនៅក្នុងកិច្ចសន្យាទិញសញ្ញាបណ្ណ។
- **សញ្ញាបណ្ណដែលអាចប្តូរបាន** (Convertible Bonds)៖ គឺជាសញ្ញាបណ្ណមួយដែលនៅឥណប្រតិ- ទាន ឬនៅក្នុងកាលបរិច្ឆេទដែលបានបញ្ជាក់ណាមួយនោះ សញ្ញាបណ្ណអាចត្រូវបានគេប្តូរទៅជា

ចំនួនណាមួយនៃភាគហ៊ុនដែលអាចបោះឆ្នោតបាននៅក្នុងក្រុមហ៊ុនសាជីវកម្ម។

- **សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ (Zero Coupon Bonds)**៖ សំដៅទៅសញ្ញាបណ្ណដែត្រូវបានបោះផ្សាយលក់នៅតម្លៃអប្បហារ (Discount) នៃតម្លៃចារឹក។ សញ្ញាបណ្ណប្រភេទនេះពុំមានបង់ការប្រាក់ទេ។ វិនិយោគិនទទួលប្រាក់ចំណេញពេលទទួលបានតម្លៃចារឹកពេលវាដល់អាយុកាល។
- **សញ្ញាបណ្ណមានអត្រាទិន្នផលខ្ពស់ (High Yield "Junk" Bonds)**៖ ជាប្រភេទសញ្ញាបណ្ណទាំងឡាយណាដែលត្រូវបានវាយតម្លៃនៅក្រោមកម្រិតវិនិយោគ (low rating)។ Junk Bonds ជាសញ្ញាបណ្ណដែលមានគុណភាពអន់ តែទទួលបានទិន្នផលខ្ពស់ដើម្បីឱ្យមានភាពសមាមាត្រនឹងការប្រថុយប្រថានក្នុងការវិនិយោគ។
- **សញ្ញាបណ្ណសន្ទស្សន៍ថ្លៃ (Indexed Bonds)**៖ សញ្ញបណ្ណទាំងនេះត្រូវបានប្រើប្រាស់ក្នុងរយៈពេលដែលមានអតិផរណាខ្ពស់។ ការទូទាត់ការប្រាក់នៃសញ្ញាបណ្ណប្រភេទនេះ ត្រូវបានធ្វើជាតារាងរៀងទៅតាមអត្រាអតិផរណា។
- **ផលបត្រពាណិជ្ជកម្ម (Commercial Paper)**៖ ជាបណ្ណបំណុលមានរយៈពេលខ្លីដែលចេញដោយក្រុមហ៊ុនសាជីវកម្មល្បីៗ។ ផលបត្រពាណិជ្ជកម្មមានកាលបរិច្ឆេទឥណប្រតិទានមួយច្បាស់លាស់ដែលមិនលើសពីមួយឆ្នាំ។ ផលបត្រពាណិជ្ជកម្មជាបណ្ណដែលមិនមានការធានា (Unsecured Promissory Note) ដែលបោះផ្សាយលក់ក្នុងតម្លៃអប្បហារ។ ការប្រាក់របស់ផលបត្រពាណិជ្ជកម្មជាធម្មតាត្រូវបង់តែនៅពេលកាលបរិច្ឆេទឥណទាន[9]។

## ១.៤. ប្រភេទទីផ្សារមូលបត្រ

ការដោះដូរមូលបត្រប្រព្រឹត្តឡើងនៅទីផ្សារមូលបត្រ ហើយទីផ្សារមូលបត្រនេះត្រូវបានគេបែងចែកជាច្រើនប្រភេទដូចខាងក្រោម។

### ១.៤.១. ទីផ្សារមូលធន (Capital Market)

គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរមូលបត្រកម្មសិទ្ធិ (Equity Securities) និង ឧបករណ៍បំណុលរយៈពេលវែងមួយចំនួនទៀត។ ជាទូទៅឧបករណ៍បំណុលរយៈពេលវែងត្រូវបានគេកំណត់ថាជាឧបករណ៍ទាំងឡាយណាដែលមានឥណទានប្រតិទានរយៈពេលមួយឆ្នាំ ឬ ច្រើនជាងមួយឆ្នាំ។

### ១.៤.២. ទីផ្សាររូបិយវត្ថុ (Money Market)

គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរតែឧបករណ៍បំណុលរយៈពេលខ្លី និងប្រាក់កម្ចី (Loan)។ ឧបករណ៍

---

9 បៀន សាំង, ២០១១, មូលដ្ឋានគ្រឹះទីផ្សារមូលបត្រ, ទំព័រ ២៧-៣៤

បំណុលរយៈពេលខ្លី ត្រូវបានគេកំណត់ថាជាឧបករណ៍ទាំងឡាយណាដែលមានឥណប្រតិទានរយៈពេលតិចជាងមួយឆ្នាំ ។

**១.៤.៣. ទីផ្សារដំបូង** ( Primary Market )

ការដាក់លក់មូលបត្រជាលើកដំបូងដោយក្រុមហ៊ុនបោះផ្សាយទៅឲ្យវិនិយោគិនត្រូវបានហៅថាជាការចែកចាយជាលើកដំបូង ។ ទីផ្សារដំបូងជាកន្លែងដែលមូលបត្រត្រូវបានលក់ជាលើកទីមួយទៅឲ្យសាធារណៈជន ហើយអ្នកទិញទទួលបានមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយដែលអាចជាក្រុមហ៊ុនសាជីវកម្ម ឬអង្គភាពរដ្ឋាភិបាលមួយដែលបានបោះលក់មូលបត្រ។ សាច់ប្រាក់សម្រាប់ទូទាត់មូលបត្រត្រូវបានបង់ទៅដល់ក្រុមហ៊ុនបោះផ្សាយ ហើយអ្នកទិញភាគហ៊ុនទាំងនេះបានក្លាយជាអ្នកកាន់កាប់ (ម្ចាស់) ភាគហ៊ុនដំបូងគេ។ ភាគហ៊ុនិកដំបូង គេអាចកាន់កាប់ភាគហ៊ុនទាំងនេះ ឬក៏អាចលក់ឲ្យអ្នកផ្សេងទៀត។ ដំណើរការលក់ភាគហ៊ុនទៅឲ្យសាធារណជនជាលើកដំបូងត្រូវបានគេស្គាល់ថា «ការនាំក្រុមហ៊ុនទៅកាន់សាធារណៈ»។ បែបនេះមានន័យថា ក្រុមហ៊ុនលែងកាន់កាប់ដោយវិនិយោគដំបូង ឬ ស្ថាបនិក (Founder) ទៀតហើយ។ ក្រុមហ៊ុនដែលលក់ភាគហ៊ុនរបស់ខ្លួនទៅកាន់សាធារណជន ត្រូវបានគេសន្មតថា «សំណើលក់មូលបត្រជាសាធារណៈ» បានកើតមានឡើង។ ចំពោះដំណើរការនៃការលក់ភាគហ៊ុនជាលើកដំបូងរបស់ក្រុមហ៊ុនមួយត្រូវបានគេហៅថា «សំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង» (Initial Public Offering) ឬ IPO។

**១.៤.៤. ទីផ្សារបន្ទាប់** ( Secondary Market )

ដោយសារវិនិយោគិនមួយចំនួនយល់ថា ការប្រើប្រាស់មូលធនរបស់ពួកគេមិនមានកាលកំណត់ណាមួយជាក់លាក់ ដូចនេះហើយភាគច្រើននៃមូលបត្រអាចចរាចរទិញ-លក់បាន។ នេះមានន័យថាភាគហ៊ុនអាចផ្លាស់ប្តូរបានដោយសេរីពីអ្នកលក់ម្នាក់ទៅអ្នកទិញម្នាក់ទៀតដោយតម្លៃកំណត់មួយដែលមានការព្រមព្រៀង និង ពេញចិត្តដោយភាគីទាំងពីរតាមរយៈការផ្តល់ភាគហ៊ុនទៅអ្នកទិញ។ បណ្ណកម្មសិទ្ធិស្របច្បាប់របស់ភាគហ៊ុននឹងត្រូវបានផ្ទេរទៅអ្នកទិញ នៅពេលដែលភាគហ៊ុនត្រូវបានផ្តល់មកភាគីអ្នកទិញ។ ការកំណត់តម្លៃ និងការផ្តល់ជូនកម្មសិទ្ធិលើមូលបត្រកើតឡើងនៅកន្លែងមួយដែលគេស្គាល់ថាជាទីផ្សារបន្ទាប់។ ទីផ្សារបន្ទាប់ជាទីកន្លែងដែលការជួញដូរមូលបត្រត្រូវបានកើតឡើងជាប្រចាំរវាងអ្នកលក់ និងអ្នកទិញមូលបត្រ។ ទឹកប្រាក់កើតចេញពីសកម្មភាពជួញដូរនេះ ត្រូវបង់ទៅឲ្យភាគហ៊ុនិកដែលលក់ មិនមែនឲ្យទៅក្រុមហ៊ុនបោះផ្សាយដំបូងនោះទេ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រមិនទទួលបានផលចំណេញជាហិរញ្ញវត្ថុពីការជួញដូរមូលបត្រកើតឡើងនៅទីផ្សារបន្ទាប់ទេ ហើយមូលបត្រទាំងអស់ដែលជួញដូរនៅលើទីផ្សារបន្ទាប់អាចត្រូវបានជួញដូរ

នៅក្នុងទីផ្សារមូលបត្រ ឬ នៅក្រៅទីផ្សារមូលបត្រដែលគេហៅថា Over the Counter (ទីផ្សាររំលងបញ្ជរ)។ វាជាមុខងារនៃ**ទីផ្សារមូល-បត្រ (Securities Exchange)** និង **ទីផ្សាររំលងបញ្ជរ (Over-the-Counter Market)** ក្នុងការផ្តល់ទីកន្លែងមួយក្នុងការកំណត់តម្លៃភាគហ៊ុន ព្រមទាំងផ្តល់មូលបត្រទៅឲ្យអ្នកទិញ[10] ។

### ១.៤.៥. ទីផ្សារមូលបត្រមានការរៀបចំ ( Organized Securities Market )

ទីផ្សារបន្ទាប់បន្សំអាចត្រូវបានរៀបចំតាមវិធីពីរយ៉ាង។ វិធីសាស្រ្តមួយគឺរៀបចំ ការផ្លាស់ប្តូរកន្លែងដែលអ្នកទិញនិងអ្នកលក់មូលបត្រ (ឬភ្នាក់ងារឬឈ្មួញកណ្តាល) ជួបគ្នានៅក្នុងទីតាំងកណ្តាលមួយដើម្បីធ្វើពាណិជ្ជកម្ម។ New York Stock Exchange (NYSE) គឺជាឧទាហរណ៍នៃទីផ្សារមូលបត្រមានការរៀបចំត្រឹមត្រូវ។

### ១.៤.៦. ទីផ្សាររំលងបញ្ជរ ( Over-the-Counter Market )

វិធីសាស្រ្តផ្សេងទៀតក្នុងការរៀបចំទីផ្សារបន្ទាប់គឺមានអ្នករកប្រាក់ចំណេញច្រើន(OTC) ទីផ្សារដែលក្នុងនោះឈ្មួញនៅទីតាំងផ្សេងៗគ្នា ដែលមានសារពើភ័ណ្ឌនៃមូលបត្រត្រៀមខ្លួនជាស្រេចក្នុងការបញ្ជាទិញនិងលក់មូលបត្រ "តាមបញ្ជរ" ចំពោះអ្នកណាដែលមករកពួកគេហើយសុខចិត្តទទួលយកតម្លៃរបស់ពួកគេ។ ពោលវាពុំមានទីតាំងច្បាស់លាស់ដូច Organized Securities Market ទេ។ ម៉្យាងទៀតពីព្រោះ OTC ប្រព្រឹត្តតាមប្រព័ន្ធកុំព្យូទ័រ ហើយអ្នកជួញដូរដឹងពីតម្លៃដែលបានកំណត់វាធ្វើឱ្យ OTC មានការប្រកួតប្រជែងខ្លាំង[11]។

## ១.៥. ស្ថាប័នសំខាន់ៗ និងស្ថាប័នបន្ទាប់បន្សំក្នុងទីផ្សារមូលបត្រនៃប្រទេសកម្ពុជា

គេត្រូវការស្ថាប័នសំខាន់ចំនួនបួន បូកផ្សំជាមួយស្ថាប័នបន្ទាប់បន្សំមួយចំនួនទៀត សហការគ្នាដើម្បីធ្វើឲ្យទីផ្សារមូលបត្រក្នុងប្រទេសកម្ពុជាអាចមានដំណើរការប្រព្រឹត្តដោយភាពរលូនបាន។ ស្ថាប័នសំខាន់ទាំងបួននោះរួមមាន៖

(១) គណៈកម្មការមូលបត្រមូលបត្រកម្ពុជា (គ.ម.ក.)

(២) ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក)

(៣) ក្រុមហ៊ុនមូលបត្រ

(៤) ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

ក្រៅពីនេះ ក៏មានក្រុមហ៊ុនមួយចំនួនដែលជាតួអង្គបន្ទាប់បន្សំដែលធ្វើឲ្យការបោះផ្សាយមូលបត្រអាច

---

10 បៀន សាំង, ២០១១, មូលដ្ឋានគ្រឹះទីផ្សារមូលបត្រ, ១៦-១៨

11 Frederic S. Mishkin និង Stanley G. Eakins, Financial Markets and Institutions, ទំព័រ ៣០៤-៣០៥, ២០១១

ទៅរួចបាន។ ក្រុមហ៊ុនទាំងនោះរួមមាន៖

- ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់
- ក្រុមហ៊ុនផ្តល់សេវាបកប្រែ
- ក្រុមហ៊ុនផ្តល់សេវាសវនកម្ម
- ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ
- ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់
- ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

### ១.៥.១. គណៈកម្មការមូលបត្រមូលបត្រកម្ពុជា (គ.ម.ក.)

គណៈកម្មការមូលបត្រកម្ពុជា (Securities and Exchange Commission of Cambodia-SECC) ដែលហៅកាត់ ថា **គ.ម.ក.** គឺជានិយ័តករ និងជាអាជ្ញាធរតែមួយគត់ដែលគ្រប់គ្រង ត្រួតពិនិត្យ និង អភិវឌ្ឍទីផ្សារមូលបត្រ តាមរយៈការបង្កើតច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធនានា។ គ្រប់អាជីវកម្មទាំងអស់ដែល ពាក់ព័ន្ធនឹងមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត និងការ ទទួលស្គាល់ពី គ.ម.ក. រួមទាំងការបោះផ្សាយលក់មូលបត្រជាសាធារណៈផងដែរ។

### ១.៥.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange-CSX) ហៅកាត់ថា ផ.ម.ក. ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវប្រព័ន្ធជាត់ទាត់និងទូទាត់ ប្រព័ន្ធរក្សាទុកមូលបត្រ និងផ្តល់នូវប្រព័ន្ធ ប្រតិបត្តិការជួញដូរមូលបត្រសម្រាប់ក្រុមហ៊ុនមូលបត្រ (ក្រុមហ៊ុនធានាទិញមូលបត្រ ពាណិជ្ជករមូលបត្រ និងឈ្មួញជើងសាមូលបត្រ) និង សមាជិករបស់ ផ.ម.ក ព្រមទាំងវិនិយោគិនទូទៅផងដែរ ដើម្បីធានាឱ្យ បាន នូវបរិយាកាសអំណោយផល គណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព ខ្ពស់ក្នុងទីផ្សារ។

### ១.៥.៣. ក្រុមហ៊ុនមូលបត្រ

ដើម្បីធ្វើការជួញដូរមូលបត្របាន វិនិយោគិនទូទៅ ត្រូវមានអត្តសញ្ញាណបណ្ណ វិនិយោគិន (Investor ID) និងគណនីជួញដូរដែលត្រូវទៅបើកនៅ ក្រុមហ៊ុនមូលបត្រ (Securities Firms) ដែលរួមមានក្រុមហ៊ុន ធានាទិញមូលបត្រ ពាណិជ្ជករមូលបត្រ និងឈ្មួញជើងសាមូលបត្រ។ ក្រុមហ៊ុនធានាទិញមូលបត្រ មានសិទ្ធ ក្នុងការសម្របសម្រួល និងជួយដល់ក្រុមហ៊ុនទាំងឡាយណាដែលមានបំណងចង់បោះផ្សាយលក់មូលបត្រ (មូលបត្រកម្មសិទ្ធ មូលបត្របំណុល និងឧបករណ៍ហិរញ្ញវត្ថុដទៃ ទៀត) ជាសាធារណៈ និងអាចធ្វើការជួញដូរ

មូលបត្រសម្រាប់គណនី ក្រុមហ៊ុនផ្ទាល់ និងជួញដូរតាមការបញ្ជារបស់វិនិយោគិន។ ចំណែកឯពាណិជ្ជករមូលបត្រ មានសិទ្ធជួញដូរមូលបត្រសម្រាប់គណនីក្រុមហ៊ុនផ្ទាល់ និងជួញដូរតាមការបញ្ជារបស់វិនិយោគិន។ ចំពោះឈ្មួញជើងសាមូលបត្រ មានសិទ្ធអាចតែធ្វើការជួញដូរតាមការបញ្ជាទិញ-លក់របស់វិនិយោគិនប៉ុណ្ណោះ។ តាមសេចក្ដីនេះក្រុមហ៊ុនមូលបត្រត្រូវបានបែងចែកជាបីប្រភេទ ពោលគឺ ក្រុមហ៊ុនធានាទិញមូលបត្រ ពាណិជ្ជករមូលបត្រ និងក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ។

ខាងក្រោមនេះជាបញ្ជីក្រុមហ៊ុនមូលបត្រ៖

**ក្រុមហ៊ុនធានាទិញមូលបត្រ៖**

- យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី
- អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា)ម.ក
- កាណា ស៊ីឃ្យូរីធី អិលធីឌី
- កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី
- អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី
- ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

**ពាណិជ្ជករមូលបត្រ**

- ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី

**ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ**

- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
- ខេប ស៊ីឃ្យូរីធី លីមីធីត
- ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ឯ.ក
- ក្រុមហ៊ុន ភីភី លីង ស៊ីឃ្យូរីធី ឯ.ក[12]

### ១.៥.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រ

ការជួញដូរមូលបត្រអាចប្រព្រឹត្តទៅបានលុះត្រាតែមានក្រុមហ៊ុនបោះផ្សាយមូលបត្រ (Issuers) ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិបោះផ្សាយលក់មូលបត្រកម្ម-សិទ្ធ មូលបត្របំណុល ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀតនៅក្នុងទីផ្សារមូលបត្រ ទៅតាមទំហំរបស់ក្រុមហ៊ុន

12 គណៈកម្មការមូលបត្រកម្ពុជា, អ្នកចូលរួមទីផ្សារ-អន្តរការីទីផ្សារ, http://www.secc.gov.kh/khmer/m52.php?pn=6, (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០២០)

ដែលចង់បោះផ្សាយ។ គោលបំណង របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ គឺដើម្បីកៀរគរមូលធនពីសាធារណៈជន ព្រមទាំងវិនិយោគិនទាំងក្នុង និងក្រៅស្រុក ក្នុងទិសដៅពង្រីកអាជីវកម្ម និងប្រតិបត្តិការអាជីវកម្មរបស់ខ្លួនប្រកបដោយស្ថិរភាព និងការប្រកួតប្រជែង ខ្ពស់ទាំងថ្នាក់ជាតិ អន្តរជាតិ និងក្នុងតំបន់[13]។ ក្រុមហ៊ុនបោះផ្សាយក៏មានតួនាទីក្នុងការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុនានាជាសាធារណៈ ដើម្បីឲ្យមហាជនទូទៅ និងវិនិយោគិនទទួលបានព័ត៌មានគ្រប់គ្រាន់មុនធ្វើការសម្រេចចិត្តវិនិយោគជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ។

គិតត្រឹមខែ មិថុនា ឆ្នាំ២០២០ មានក្រុមហ៊ុនចំនួន ៦ ដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនទាំងនោះរួមមាន៖

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី
- កំពង់ផែស្វយ័តភ្នំពេញ
- ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី)
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស)
- ធនាគារ អេស៊ីលីដា ភីអិលស៊ី

### ១.៥.៥. ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់

ក្រុមហ៊ុន និងការិយាល័យមេធាវីចំនួន ១៤ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. រួមមាន៖

| **ក្រុមហ៊ុន** | **មេធាវីទទួលស្គាល់គុណវុឌ្ឍិពី គ.ម.ក.** |
|---|---|
| ១. ក្រុមហ៊ុនមេធាវី អេច ប៊ី អេស | - លោក លី តៃសេង<br>- លោក ហាក់ សៀកលី |
| ២. ការិយាល័យមេធាវី អ អេន ធី សុខ អេន ហេង | - លោក ទីវ សុផុណ្ណារ៉ា<br>- លោក ហេង ឆាយ |
| ៣. ការិយាល័យមេធាវី សុក ស៊ីផាន់ណា និង សហការីជាសមាជិក ZICOlaw | - លោក សុក ស៊ីផាន់ណា<br>- លោកស្រី ខៀវ មាលី |

13 គណៈកម្មការមូលបត្រកម្ពុជា, ពុទ្ធិមូលបត្រ លេខ ៣៩, តួនាទីរបស់គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនបោះផ្សាយមូលបត្រ, ២០១៩

| | |
|---|---|
| ៤. ការិយាល័យមេធាវី សិទ្ធិស័ក្តិ | - លោក ម៉ុក ច័ន្ទសុធា |
| | - លោក តាន់ ម៉េងស្រួយ |
| | - លោកស្រី ប៉េង ម៉ាណែត |
| | - លោក សុន សុខកេង |
| ៥. ក្រុមមេធាវី អាស៊ី កម្ពុជា | - លោកស្រី សេង វួចហ៊ុន |
| | - លោក យិន សារ៉ុម |
| ៦. ការិយាល័យមេធាវី ប៊ុន និង សហការី | - លោក ប៊ុន យូឌី |
| | - លោក ឈិត វិនា |
| ៧. ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី | - លោក យុន ប៉ោទឹម |
| | - កញ្ញា ទ្រី សំរស់ |
| ៨. ការិយាល័យមេធាវី ស៊ី អេស អែល និងសហភាគា | - លោក ជា សុម៉ាឡា |
| | - លោក ឆេង វណ្ណី |
| ៩. ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន | - កញ្ញា ម៉ៅ សំរុទ្ធារី |
| | - កញ្ញា កង លាប |
| ១០. ការិយាល័យមេធាវី ស៊ិន & ផាតនើ | -លោក ស៊ិន សុពុទ្ធិ |
| | - លោកស្រី ឈឹម សំអុល |
| ១១.  ក្រុមមេធាវី កម្ពុជាបាយ័ន (ស៊ី ប៊ី អិល) | -លោក ថាន ផានិត |
| | - លោក ម៉ម វិទ្ធា |
| | - លោក ឈន សុងមេង |

១២. ក្រុមមេធាវី មេគង្គ - លោក គង់ ឈុង
- លោកស្រី ចាន់ ផូវឌ្បនះ

១៣. ក្រុមមេធាវី កម្ពុជាសហប្រតិបត្តិការអន្តរជាតិ - លោក លី វឌ្ឍធី
- លោក សេង ឈុនលី

១៤. ក្រុមមេធាវី ស៊ី អេស ភី និង សហការី - លោកស្រី ចាំង ស្រីពៅ
- លោកស្រី គង់ កន្និកា

### ១.៥.៦. ក្រុមហ៊ុនផ្តល់សេវាបកប្រែ

ក្រុមហ៊ុនផ្តល់សេវាបកប្រែនៅក្នុងវិស័យមូលបត្រក្នុងប្រទេសកម្ពុជាដែលទទួលស្គាល់ដោយ គ.ម.ក. មានចំនួនតែ ១ ប៉ុណ្ណោះ។ ស្ថាប័ននោះគឺ មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ហើយអ្នកទទួលខុសត្រូវលើការបកប្រែមានចំនួន ២ រូបគឺ៖

- លោក តាន់ហ៊ាង ដារ័ណ្ណ
- លោក យិន លីហួត។

### ១.៥.៧. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលស្គាល់ដោយ គ.ម.ក មានដូចខាងក្រោម៖

| ក្រុមហ៊ុន | សវនករឯករាជ្យ |
|---|---|
| ១. ក្រុមហ៊ុន ប្រាយវ៍តេជ័រ ហាវខូភើស៍ (ខេមបូឌា) | - លោក គុយ លីម |
| | - លោកស្រី Benilda Fernando |
| | - លោក ឡាង ហ៊ី |
| ២. ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា | - លោក ង៉ែ ហ៊ុយ |
| | - កញ្ញា តាំង យុគហ្វុង |
| | - លោក សេង ចាន់ថន |
| | - លោក សុង គន្ធុល |
| | - លោកស្រី ហ្កេក ទាវ |

- កញ្ញា Lim Chew Teng

៣. ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត
- លោក Gan Ah Tee
- លោក Tang Seng Choon
- លោក Law Kian Huat
- លោក Lim Seng Siew
- លោក Lee Ken Wai

៤. ក្រុមហ៊ុន អឺនស្ទ័ អ៊ែន យ៉ាំង (ខេមបូឌា)
- លោកស្រី ឡូន ស៊ីនរតនា
- លោកស្រី Maria Cristina Calimbas
- លោក Cuong Dinh Tran
- កញ្ញា Mary Rose S.Romero

៥. ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
- លោក Jasani Narendrakumar
- លោក Hooi Kok Mun
- លោក Almera Ronald Coronel
- លោក Tan Chee Beng
- លោក Ng Yee Zent

៦. ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក
- លោក Poon Yew Hoe
- លោក Onn Kien Hoe
- លោក Chan Kuan Chee

៧. ក្រុមហ៊ុន ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី
- លោក ខូយ គឹមលេង
- លោក អ៊ឹង គឹមសុភ័ក្ត្រា
- លោក Ho Kok Yong

៨. ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក - លោក TAN KHEE MENG
- លោក ANDREW HENG
- លោក FU JOE HENG
- លោក LOCK PENG KUAN

### ១.៥.៨. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ

ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃមានតួនាទីវាយតម្លៃ ទ្រពសកម្ម ដោយអនុវត្តឲ្យបាននូវស្តង់ដាដែលបានកំណត់។ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលស្គាល់ដោយ ក.ម.ក. មាន៖

- ក្រុមហ៊ុន វីត្រាស់ អីព្រេហ្សល
- ក្រុមហ៊ុន ស៊ីងឈ័រ ប្រូធឺធី ឯ.ក
- ក្រុមហ៊ុន ណាយ ហ្វ្រេង (ខេមបូឌា)។

### ១.៥.៩. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដូចជាការផ្ទេរ ឬការបង្វែរសាច់ប្រាក់រវាងតួភាគីជួញដូរប្រកបដោយសុវត្ថិភាព និងត្រូវបំពេញប្រតិបត្តិការឲ្យដាច់ដោយឡែកពីប្រតិបត្តិការធនាគារ។ ភ្នាក់ងារនេះដែលមានការទទួលស្គាល់ពី គ.ម.ក. រួមមាន៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
- ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
- ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី
- ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក។

### ១.៥.១០. បញ្ជីឈ្មោះភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

ភ្នាក់ងារបញ្ជិកាមូលបត្រមានតួនាទីគ្រប់គ្រងនូវដំណើរការបរិវិសកម្ម ការបែងចែកមូលបត្រ កត់តាបញ្ជីកម្មសិទ្ធិករមូលបត្រ និងធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រ។ ចំណែកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ធ្វើការរក្សា គ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រឲ្យមានសង្គតិភាព និងធ្វើការងាររដ្ឋបាលពាក់ព័ន្ធនឹងការផ្លាស់ប្តូរកម្មសិទ្ធិ។ ឯភ្នាក់ងារទូទាត់វិញមានតួនាទីគណនា ភាគលាភ ការប្រាក់ និង

ប្រាក់ដើម។ ភ្នាក់ងារនេះតំណាងឲ្យក្រុមហ៊ុនបោះផ្សាយ ធ្វើការទូទាត់ជូនម្ចាស់មូលបត្រករ និងភាគីផ្សេងៗ។

ភ្នាក់ងារទាំងនេះដែលមានការទទួលស្គាល់ពី គ.ម.ក. មាន៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី ស៊ីរីស ភីអិលស៊ី
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

### ១.៥.១១. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល

ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលសំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ដើម្បីធ្វើជាភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ស្របទៅតាមបទប្បញ្ញត្តិដែលមានជាធរមាន[14]។ ភ្នាក់ងារដែលទទួលស្គាល់ពី គ.ម.ក. មាន៖

- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី[15]

## ១.៦. យន្តការចូលទីផ្សារមូលបត្រជាសាធារណៈ

ជាទូទៅក្រុមហ៊ុនត្រូវអនុវត្តតាមយន្តការទាំង១២ មុននឹងអាចឈានជើងចូលក្នុងទីផ្សារមូលបត្រកម្ពុជា និងអាចបោះផ្សាយលក់មូលបត្រជាលើកដំបូង (IPO) ជាសាធារណៈបាន។ យន្តការទាំង១២ នោះរួមមាន៖

**យន្តការទី១៖** ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈអាចដាល់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក គណៈកម្មាការមូលបត្រកម្ពុជា (គ.ម.ក.) ដែលលិខិតមានខ្លឹមសារ 03 ចំណុចដូចខាងក្រោម៖ (ទម្រង់លិខិតមានក្នុងឧបសម្ព័ន្ធ ១)

១. គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២. គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

៣. ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមានក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

14 គណៈកម្មការមូលបត្រកម្ពុជា, ប្រកាស លេខ ០០៩/១៧ ស្តីពី ការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ, ២០១៧

15 គណៈកម្មការមូលបត្រកម្ពុជា, អ្នកចូលរួមទីផ្សារ, http://www.secc.gov.kh, (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០២០)

**យន្តការទី២៖** ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់មួយ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាកម្មដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក។

**យន្តការទី៣៖** ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុម-ហ៊ុនផ្តល់សេវាវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ដើម្បីចូលរួមក្នុងការងារបោះផ្សាយលក់នូវមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនធានាទិញមូលបត្រអាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើស ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើស-រើសបាន ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

**យន្តការទី៤៖** ការត្រួតពិនិត្យបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)

ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈលើកដំបូងដែលរួមមាន ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

**យន្តការទី៥៖** ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។

**យន្តការទី៦៖** ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក.

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំឯកសារដាក់ពាក្យដើម្បីស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មានមុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជនក្រុមហ៊ុនបោះផ្សាយ។

**យន្តការទី៧៖** ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រ ជាសាធារណៈ ពី គ. ម. ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគមុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**យន្តការទី៨៖** ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របានដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**យន្តការទី៩៖** ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនានានៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន គ.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**យន្តការទី១០៖**- ការធ្វើបរិវិសកម្មមូលបត្រ (Subscription)

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិស-

កម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**យន្តការទី១១៖** ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍របស់លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្ជាមជូនមក គ.ម.ក.។

**យន្តការទី១២៖** ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។[16]

16 គោលការណ៍ណែនាំស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងលេខ ០០១ ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១១

# ជំពូកទី២៖
# ទិដ្ឋភាពទូទៅរបស់
# ធនាគារអេស៊ីដា

# ជំពូកទី២៖ ទិដ្ឋភាពទូទៅរបស់ធនាគារអេស៊ីលីដា

## ២.១. ប្រវត្តិសង្ខេបអេស៊ីលីដា និងប្រវត្តិការបង្កើតសាខារបស់ធនាគារអេស៊ីលីដា

### ២.១.១. ប្រវត្តិសង្ខេបអេស៊ីលីដា

អេស៊ីលីដា ត្រូវបានបង្កើតឡើងនៅក្នុងខែមករា ឆ្នាំ១៩៩៣ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយមានទិសដៅអភិវឌ្ឍន៍មុខរបរខ្នាតតូចបំផុត និងខ្នាតតូច តាមរយៈការផ្តល់ឥណទាន ដោយមានការជួយគាំទ្រពីអង្គការពលកម្មអន្តរជាតិ (ILO) និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)។ តាំងពីពេលចាប់ផ្តើមដំបូង អេស៊ីលីដាបានទទួលការគាំទ្រពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសំខាន់ៗជាច្រើន។ មានកត្តាធំពីរដែលធ្វើឱ្យក្រុមប្រឹក្សាភិបាល និងដៃគូអន្តរជាតិរបស់ខ្លួនសម្រេចថា ធនាគារ អេស៊ីលីដា គួរធ្វើការកម្លាយខ្លួនទៅជាធនាគារពាណិជ្ជ ហើយកត្តាទាំងនោះគឺការពង្រីកបណ្តាញប្រតិបត្តិការគ្របដណ្តប់គ្រប់ខេត្ត-រាជធានីក្នុងព្រះរាជាណា-ចក្រកម្ពុជា និងសមត្ថភាពរបស់ធនាគារ ក្នុងការរកប្រាក់ចំណេញដែលធានានូវនិរន្តរភាព។ ធ្វើបែបនេះ មិនត្រឹមតែជួយពង្រឹងស្ថិរភាពរចនាសម្ព័ន្ធផ្នែកច្បាប់សម្រាប់បំពេញកាតព្វកិច្ចរបស់ខ្លួនពីមុនមកនោះទេ វាថែមទាំងផ្តល់ឲ្យធនាគារនូវជម្រើសកាន់តែច្រើនក្នុងការរកទុនបន្ថែម (ដូចជាការបន្ថែមដើមទុន ការទទួលប្រាក់បញ្ញើសាធារ-ណៈ ឬការទទួលប្រាក់កម្ចីពាណិជ្ជកម្ម រវាងធនាគារដូចគ្នា) សម្រាប់គាំទ្រដល់ការពង្រីក ការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដែលជាអាជីវកម្មស្នូលរបស់ខ្លួន។ ដោយមានការជួយជ្រោមជ្រែងពីស្ថាប័នមួយចំនួនដូចជា ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក (USAID) កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF/IFC) និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ធកម្មវិធីកម្លាយខ្លួនរយៈពេលបីឆ្នាំ ត្រូវបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៩៨ ហើយសម្រេចជោគជ័យ ដោយទទួលបានអាជ្ញាប័ណ្ណជាធនាគារឯកទេស នៅក្នុងខែតុលា ឆ្នាំ២០០០។

នៅក្នុងដំណើរការកម្លាយខ្លួននេះ អង្គការក្រៅរដ្ឋាភិបាលអេស៊ីលីដាដើម បានបង្វែរទ្រព្យសកម្ម និងបំណុលក្នុងដៃអតិថិជន (ប្រាក់កម្ចីរយៈពេលវែង ដែលទទួលបានពីម្ចាស់ជំនួយ) ទៅកាន់ធនាគារ អេស៊ីលីដា ដែលទើបបង្កើតថ្មី ដោយប្តូរត្រឡប់ទៅវិញជាភាគហ៊ុន ៤៤,៩១% របស់ធនាគារស្មើ ៤ លានដុល្លារអាមេរិក។ សមាគមបុគ្គលិកអេស៊ីលីដា (ក្រុមហ៊ុន អេ អេស អេ អ៊ីន្ស) ដែលបានបង្កើតឡើងដោយមូលនិធិរបស់បុគ្គលិកបានទិញភាគហ៊ុនចំនួន ៦,០៩% ហើយចំណែកដែលនៅសល់ ៤៩% ទៀតត្រូវបានបែងចែកទៅឱ្យភាគទុនិកបរទេសចំនួនបួនគឺ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (សាខារបស់ធនាគារពិភពលោក), DEG (ប្រទេសអាល្លឺម៉ង់), FMO និង ធនាគារទ្រីយ៉ូដូស (ប្រទេសហុល្លង់ដ៍) ។

បន្ទាប់ពីបង្កើនដើមទុនរបស់ខ្លួនមួយទ្វេរជាបី ឡើងដល់ ១៣លានដុល្លារអាមេរិក ធនាគារអេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ហើយត្រូវប្តូរឈ្មោះមកជា "ធនាគារ អេស៊ីលីដា ភីអិលស៊ី"។

នាដំណាច់ឆ្នាំ២០១៩ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានទ្រព្យសកម្មសរុប ៦.១៧៥ លានដុល្លារ អាមេរិក ព្រមទាំងកាន់កាប់ទីផ្សារបានប្រមាណ ១៤,៣% នៃទីហំទ្រព្យសកម្មសរុប, ១៤,៨% (សមតុល្យ-ឥណទាន) និង ៤៥,៨% (ចំនួនអតិថិជន) នៃទំហំទីផ្សារឥណទានសរុប, និង ១៦,៥% (សមតុល្យប្រាក់បញ្ញើ) និង ៤៨,២% (ចំនួនគណនី) នៃទំហំទីផ្សារប្រាក់បញ្ញើសរុប នៅក្នុងវិស័យធនាគារនៅក្នុងប្រទេសកម្ពុជា (មិនរាប់បញ្ចូលស្ថាប័នមីក្រូហិរញ្ញវត្ថុ និងអង្គការក្រៅរដ្ឋាភិបាល) ។ បច្ចុប្បន្នធនាគារអេស៊ីលីដាមានសមតុល្យឥណទានសរុបប្រមាណ ៣៧៧៧,៥៤លានដុល្លារអាមេរិក នៅលើដៃអតិថិជនជាង ៤០៨ ០៧៥ នាក់ ដែលក្នុងនោះមាន ៥៥,៤៣% ជាស្ត្រី ។ ធនាគារមានបុគ្គលិកសរុប ១២ ១១៩នាក់ កំពុងបម្រើការងារ នៅក្នុង ២៦៣សាខា ដែលគ្របដណ្តប់គ្រប់ខេត្ត-រាជធានីនៃព្រះរាជាណាចក្រកម្ពុជា[17]។

នៅថ្ងៃទី២៥ ឧសភា ២០២០ ធនាគារអេស៊ីលីដា ភីអិលស៊ីបានបោះផ្សាយមូលបត្រកម្មសិទ្ធរបស់ខ្លួនជាផ្លូវការនៅទីផ្សារមូលបត្រកម្ពុជា។

**តារាងទី១៖** ប្រវត្តិសង្ខេបនៃការវិវត្តន៍របស់ធនាគារអេស៊ីលីដា

| កាលបរិច្ឆេទ | ប្រភេទស្ថាប័ន |
|---|---|
| ១៩ មករា ១៩៩៣ - ១៨ កុម្ភៈ ១៩៩៥ | សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អង្គការក្រៅរដ្ឋាភិបាល) |
| ១៩ កុម្ភៈ ១៩៩៥ - ០៥ តុលា ២០០០ | សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (ស្ថាប័នមីក្រូហិរញ្ញវត្ថុ) |
| ០៦ តុលា ២០០០ - ៣០ វិច្ឆិកា ២០០៣ | ធនាគារ អេស៊ីលីដា (ធនាគារឯកទេស) |
| ០១ ធ្នូ ២០០៣ - ២៤ ឧសភា ២០២០ | ធនាគារ អេស៊ីលីដា ភីអិលស៊ី (ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត |

17 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ព័ត៌មានអំពីធនាគារ-សេចក្តីសង្ខេប, https://www.acledabank.com.kh/kh/khm/ff_history, (ចូលទស្សនាថ្ងៃទី ១៥ មិថុនា ២០២០)

| | |
|---|---|
| ២៥ ឧសភា ២០២០ - ២០២០ | ធនាគារ អេស៊ីលីដា ភីអិលស៊ី (ក្រុមហ៊ុនសាជីវកម្ម) |

### ២.១.២. ប្រវត្តិការបង្កើតសាខារបស់ធនាគារអេស៊ីលីដា

ដូចដែលបានរៀបរាប់ខាងលើ ធនាគារអេស៊ីលីដាចាប់បដិសន្ធិជាអង្គការក្រៅរដ្ឋាភិបាលមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ១៩៩៣។ ចាប់តាំងពីពេលនោះមកមានការវិវត្តជាច្រើនដែលរួមមានទាំងស្ថាប័ន និងសាខារបស់អេស៊ីលីដា។ តារាងខាងក្រោមបង្ហាញអំពីការបោះជំហានក្នុងការបង្កើតសាខាថ្មីៗជាបន្តបន្ទាប់នៅតាមបណ្តាលខេត្តក្រុងនានារបស់ប្រទេសកម្ពុជា។

**តារាងទី២៖** ប្រវត្តិការបង្កើតសាខារបស់ធនាគារ អេស៊ីលីដា

| ឆ្នាំ | ខេត្ត និងក្រុងដែលត្រូវបានពង្រីកសាខាធនាគារ |
|---|---|
| ១៩៩៣ | ភ្នំពេញ កណ្តាល បន្ទាយមានជ័យ សៀមរាប បាត់ដំបង កំពង់ចាម |
| ១៩៩៤ | តាកែវ កំពត កែប |
| ១៩៩៥ | ក្រុងព្រះសីហនុ |
| ១៩៩៦ | ពោធិ៍សាត់ |
| ១៩៩៧ | កំពង់ស្ពឺ កំពង់ធំ |
| ២០០០ | កំពង់ឆ្នាំង ស្វាយរៀង |
| ២០០១ | ព្រៃវែង |
| ២០០៣ | កោះកុង |
| ២០០៤ | ប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ ក្រចេះ |
| ២០០៥ | ស្ទឹងត្រែង |
| ២០០៦ | រតនគិរី មណ្ឌលគិរី |

## ២.២. រូបសញ្ញា និងអត្ថន័យរបស់ធនាគារអេស៊ីលីដា

### ២.២.១. រូបសញ្ញាបច្ចុប្បន្ន របស់ធនាគារអេស៊ីលីដា

**រូបភាពទី១៖** រូបសញ្ញាបច្ចុប្បន្នធនាគារអេស៊ីលីដា

### ២.២.២. អត្ថន័យ របស់ធនាគារអេស៊ីលីដា

អត្ថន័យរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺ៖

- អ = អភិសមាចារ អភិវឌ្ឍន៍ អច្ឆរិយ
- ស = សុខភាព សមត្ថភាព សីលធម៌
- ល = លឿនទាន់ចិត្ត លទ្ធផលល្អ លើសលប់
- ដ = ដឹងយល់ ដុះដាល ដល់គោលដៅ

### ២.២.៣. រូបសញ្ញាពីអតីតកាល របស់ធនាគារអេស៊ីលីដា

**រូបភាពទី២៖** រូបសញ្ញាធនាគារអេស៊ីលីដាពីអតីតកាល[18]




## ២.៣. រូបសញ្ញាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ ធនាគារអេស៊ីលីដា

ធនាគារ អេស៊ីលីដា មានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន ៤ គឺ ធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ មីយ៉ាន់ម៉ា, អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី, និងវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា។

**រូបភាពទី៣៖** រូបសញ្ញាធនាគារអេស៊ីលីដា រួមនិងរូបសញ្ញារបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ




## ២.៤. ទស្សនៈ និងបេសកកម្ម

18 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ព័ត៌មាន - និមិត្តសញ្ញា, https://www.acledabank.com.kh/kh/khm/md_logo, (ចូលទស្សនាថ្ងៃទី ១៥ មិថុនា ២០២០)

### ២.៤.១. ទស្សនៈ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ។

### ២.៤.២. បេសកកម្ម

បេសកកម្មរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជន នូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីល-ធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និង បរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត។

## ២.៥. ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ធនាគារអេស៊ីដា រួមមានលោក ឆាយ សឿន ដែលត្រូវជាប្រធានក្រុមប្រឹក្សាភិ-បាលប្តូរវេន និងបណ្ឌិត អ៊ិន ចាន់នី លោក វ័ត្ន យូម៉េង បណ្ឌិត Pieter Kooi លោក Cornelius Reinhart Gunter Obert លោក Ian Samuel Lydall លោក Stephane Mangiavacca លោក Kenichiro Mori និង លោកស្រី Mirjan Janssen ជាអភិបាល[19]។

**រូបភាពទី៤៖** ក្រុមប្រឹក្សាភិបាលធនាគារអេស៊ីលីដា




## ២.៦. គណៈកម្មាធិការប្រតិបត្តិ

រូបភាពខាងក្រោមរាយនាម និងតួនាទីសមាជិកគណៈកម្មាធិការប្រតិបត្តិរបស់ធនាគារ អេស៊ីលីដា។

19 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ព័ត៌មានអំពីធនាគារ - ក្រុមប្រឹក្សាភិបាល, https://www.acledabank.com.kh/kh/khm/ff_bod, (ចូល ទស្សនាថ្ងៃទី ១៧ មិថុនា ២០២០)

**រូបភាពទី៥៖** គណៈកម្មាធិការប្រតិបត្តិធនាគារអេស៊ីលីដា.[20]




## ២.៧. សេវាកម្ម និងផលិតផល

ធនាគារ អេស៊ីលីដា ភីអិលស៊ីបានកែច្នៃផលិតផល និងសេវារបស់ខ្លួនដើម្បីឱ្យសមស្របនឹងតម្រូវការរបស់អតិថិជន។ អេស៊ីលីដាមានផលិតផលដែលសំបូរបែប ដែលដើរទន្ទឹមនឹងបច្ចេកវិទ្យាស្តង់ដាពិភពលោកដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជា។

ផលិតផល និងសេវារបស់ធនាគាររួមមានដូចតទៅ។

### ២.៧.១. សេវាធនាគារអេឡិចត្រូនិច

សេវាធនាគារអេឡិចត្រូនិចមានដូចតទៅ៖

- សេវាអេស៊ីលីដាអ៊ីនធើណែតៈ ជាប្រព័ន្ធបច្ចេកវិជ្ជាទំនើប ផ្តល់ជូនអតិថិជនក្នុងការចាត់ចែងសាច់ប្រាក់ និងធ្វើប្រតិបត្តិការសេវាធនាគារ តាមរយៈកុំព្យូទ័រដែលមានភ្ជាប់ប្រព័ន្ធអ៊ីនធើណែត បានតាមតម្រូវការ នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ប្រកបដោយភាពងាយស្រួលនិងសុវត្ថិភាពខ្ពស់។
- សេវាអេស៊ីលីដាយូនីធីទាន់ចិត្តៈ ជាសេវាហិរញ្ញវត្ថុមួយប្រភេទដែលអនុញ្ញាតឲ្យអតិថិជន ក៏ដូចជាសាធារណជនទូទៅ ដែលធ្លាប់ ឬមិនធ្លាប់ប្រើសេវាធនាគារពីមុនមកជាមួយធនាគារ អេស៊ីលីដា ឬធនាគារផ្សេង អាចធ្វើប្រតិបត្តិការសេវាធនាគារ តាមរយៈទូរស័ព្ទចល័តដែលដំណើរការដោយ Android និង iOS។
- សេវាអេស៊ីលីដាអីខុមមើស (E-Commerce)៖ សម្រាប់ផ្តល់មធ្យោបាយឱ្យក្រុមហ៊ុន/អង្គភាព (ពាណិជ្ជករ) អាចលក់ទំនិញ-សេវាកម្មតាមប្រព័ន្ធអ៊ីនធើណែត (Online Shopping) និងអនុញ្ញាត

---

20 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ព័ត៌មានអំពីធនាគារ-គណៈកម្មាធិការប្រតិបត្តិ, https://www.acledabank.com.kh/kh/khm/ff_mgt, (ចូលទស្សនាថ្ងៃទី ១៧ មិថុនា ២០២០)

ឱ្យអតិថិជនដែលជាម្ចាស់ប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទាន អាចបញ្ជាទិញ និងទូទាត់បានភ្លាមៗ តាមប្រព័ន្ធធនាគារអេឡិចត្រូនិក។

- ប័ណ្ណឥណទានប្រើប្រាស់ផ្ទាល់ខ្លួន៖ ជាប័ណ្ណដែលចេញដោយធនាគារអេស៊ីលីដា ដើម្បីផ្តល់ជូនអតិថិ-ជនអាចធ្វើប្រតិបត្តិការដកសាច់ប្រាក់ពីម៉ាស៊ីនអេធីអឹម ព្រមទាំងអាចទូទាត់ថ្លៃទំនិញ-សេវាកម្មផ្សេងៗតាមរយៈម៉ាស៊ីនឆូតកាតអេស៊ីលីដា ឬប្រព័ន្ធអេស៊ីលីដាអ៊ីខុមមើស លើសពីសមតុល្យទឹកប្រាក់ដែលមានជាក់ស្តែងក្នុងគណនី។
- ប័ណ្ណអេស៊ីលីដា៖ ប័ណ្ណអេធីអឹមធអេស៊ីលីដា គឺជាប័ណ្ណចេញដោយធនាគារអេស៊ីលីដា ជូនដល់អតិថិ-ជនដើម្បីធ្វើប្រតិបត្តិការតាមម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ (ATM) នៅក្នុងប្រទេសកម្ពុជា និងឡាវ និងតាមម៉ាស៊ីនឆូតកាត របស់ធនាគារអេស៊ីលីដា ២៤ ម៉ោងក្នុងមួយថ្ងៃ និង ៧ ថ្ងៃក្នុងមួយសប្តាហ៍ ប្រកបដោយភាពងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាពខ្ពស់បំផុត ។
- ប័ណ្ណវីសា, ម៉ាស្ទ័រកាត, ចេស៊ីប៊ី, ឬ យូនីអាយអេស៊ីលីដា៖ ជាជម្រើសទូទាត់ដ៏ប្រសើរ និងទំនើបទាន់សម័យ តាមរយៈម៉ាស៊ីនឆូតកាត, e-commerce, ឬដកសាច់ប្រាក់តាមម៉ាស៊ីនអេធីអឹម ដែលមានបិទស្លាកសញ្ញា VISA, Mastercard, JCB, ឬ UnionPay នៅទូទាំងប្រទេស និងពិភពលោក។
- ម៉ាស៊ីនអេធីអឹម អេស៊ីលីដា៖ ម៉ាស៊ីនអេធីអឹម អេស៊ីលីដា អនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការសេវាធនាគារ បានគ្រប់ពេលវេលា (២៤ម៉ោងក្នុងមួយថ្ងៃ និង ៧ថ្ងៃក្នុងមួយសប្តាហ៍) មានលក្ខណៈងាយស្រួល និងសុវត្ថិភាពខ្ពស់បំផុត តាមរយៈប័ណ្ណរបស់ធនាគារអេស៊ីលីដា និងប័ណ្ណរបស់ធនាគារផ្សេងដែលជាសមាជិក CSS VISA Mastercard UnionPay JCB Diners Club។
- ម៉ាស៊ីនឆូតកាតអេស៊ីលីដា៖ ជាឧបករណ៍អេឡិចត្រូនិកដែលប្រើជាមួយ ប័ណ្ណអេស៊ីលីដា ឬប័ណ្ណធនាគារផ្សេង សម្រាប់ទូទាត់ទំនិញ ឬសេវាកម្មផ្សេងៗដែលមានលក្ខណៈងាយស្រួល និងសុវត្ថិភាពខ្ពស់បំផុត។
- សេវាបញ្ចូលទឹកប្រាក់៖ អតិថិជនអាចបញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទ ឬសេវាផ្សេងៗទៀត តាមរយៈ**សេវាអេស៊ីលីដាទាន់ចិត្ត សេវាអេស៊ីលីដាអ៊ីនធើណែត** និង**អេធីអឹម** បានគ្រប់ពេលវេលានិងមានងាយស្រួលបំផុត។
- សេវាបញ្ជាតាមរយៈ Email/Fax៖ អនុញ្ញាតឱ្យអតិថិជនដែលជាម្ចាស់គណនីអាចផ្ញើ E-mail/Fax មកកាន់ធនាគារអេស៊ីលីដាដើម្បីស្នើសុំធ្វើប្រតិបត្តិការគណនីពីចម្ងាយដូចជា៖ **ផ្ទេរ ប្រាក់**, **ទូទាត់**, **ដកប្រាក់ពីគណនី** ឬប្រតិបត្តិការផ្សេងៗទៀតតាមបំណងផ្ទាល់របស់ម្ចាស់គណនីបានយ៉ាងងាយ។

- សេវាផ្ញើសារជូនដំណឹងព័ត៌មានគណនី៖ សេវាផ្ញើសារជូនដំណឹងព័ត៌មានគណនី គឺជាការជូនដំណឹងពីធនាគារអេស៊ីលីដា ទៅកាន់អតិថិជនម្ចាស់គណនីតាមរយៈទូរស័ព្ទដៃ ។ សារជូនដំណឹងខ្លីៗអំពីព័ត៌មានគណនី នឹងផ្ញើជាស្វ័យប្រវត្តិ បន្ទាប់ពីមានប្រតិបត្តិការកើតឡើងលើគណនីរបស់អតិថិជន ដូចជាប្រតិបត្តិការដាក់-ដកជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ, ផ្ទេរប្រាក់ (ក្នុងនិងក្រៅប្រទេស), បញ្ញាអ-ចិន្ត្រៃយ៍, ឥណទានវិបារូបរ៍ (គណនីចរន្ត), ឬទូទាត់ផ្សេងៗ ទាំងនៅតាមបញ្ជរធនាគារអេស៊ី-លីដា និងតាមរយៈសេវាធនាគារអេឡិចត្រូនិក (អេធីអឹម, ម៉ាស៊ីនឆូតកាត, អេស៊ីលីដាអ៊ីនធើណែត, និង e-commerce)[21]។

## ២.៧.២. សេវាឥណទាន

ធនាគារអេស៊ីលីដា ភីអិលស៊ី គឺជាប្រភពផ្តល់ប្រាក់កម្ចីដ៏មានទំនុកចិត្តដើម្បីទ្រទ្រង់មុខរបរជំនួញរបស់អតិថិជនឱ្យមានការរីកចម្រើន និងធ្វើឱ្យបំណងប្រាថ្នារបស់ពួកគាត់ក្លាយជាការពិត ។ ការប្រើប្រាស់ផលិតផល និងសេវារបស់ធនាគារអេស៊ីលីដា ភីអិលស៊ី មិនត្រឹមតែជាមធ្យោបាយដ៏ប្រសើរសម្រាប់មុខរបរជំនួញរបស់អតិថិជនប៉ុណ្ណោះទេ ថែមទាំងអាចឱ្យពួកគាត់បង្កើនជីវភាពរស់នៅ ក៏ដូចជាសុភមង្គលគ្រួសារកាន់តែប្រសើរឡើងទៀតផង។

សេវាឥណទានរបស់អេស៊ីលីដាមានច្រើនប្រភេទដូចខាងក្រោម៖

- ឥណទានអាជីវកម្មខ្នាតតូច
- ឥណទានអាជីវកម្មខ្នាតមធ្យម និងសាជីវកម្ម
- ឥណទានវិបារូបរ៍ (Overdraft)
- ឥណទានវិបារូបរ៍សម្រាប់អតិថិជនបញ្ញើ-សន្សំ
- ឥណទានសម្រាប់ទុនបង្វិល
- សេវាហិរញ្ញប្បទានគម្រោងក្នុងស្រុក
- ឥណទានពាណិជ្ជកម្ម
- ឥណទានសម្រាប់កិច្ចធានា
- ឥណទានសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន
- ឥណទានគេហដ្ឋាន

21 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ផលិតផល និងសេវា - សេវាធនាគារអេឡិចត្រូនិក, https://www.acledabank.com.kh/kh/khm/ps_ebanking, (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ២០២០)

- ឥណទានកែលម្អលំនៅឋាន
- ឥណទានរថយន្ត
- ឥណទានម៉ូតូ
- ឥណទាននិស្សិត[22]។

### ២.៧.៣. សេវាបញ្ញើ - សន្សំ

សេវានេះផ្តល់ជូនចំពោះ នីតិជនដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ និងនីតិបុគ្គលផងដែរ។ ប្រភេទគណនីបញ្ញើ - សន្សំរបស់ធនាគារ អេស៊ីលីដា រួមមាន៖

- គណនីបញ្ញើសំចៃ
- គណនីបញ្ញើតាមតម្រូវការ
- គណនីចរន្ត
- គណនីមានកាលកំណត់
- គណនី Euro Flex
- គណនីមូលបត្រ
- គណនីមូលនិធិសោធននិវត្តន៍
- គណនីមូលនិធិគាំពារសុខភាព
- គណនីមូលនិធិសិក្សាអប់រំ
- គណនី Trust សម្រាប់ទិញ-លក់អចលនទ្រព្យ
- គណនីព្រះសង្ឃ និងគណនីមូលនិធិវត្ត
- គណនីអនាគតកុមារ[23]។

### ២.៧.៤. សេវាផ្ទេរប្រាក់

សេវាផ្ទេរប្រាក់ គឺជាសេវាមួយដែលធនាគារអនុញ្ញាតឱ្យអតិថិជនធ្វើការផ្ទេរ ឬទទួលសាច់ប្រាក់ទូទាំងប្រទេស និងផ្ទេរ ឬទទួលប្រាក់ពីក្រៅប្រទេស។ បច្ចុប្បន្ននេះធនាគារអេស៊ីលីដាមានបម្រើសេវាផ្ទេរប្រាក់ដូច

22 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ផលិតផល និងសេវា - សេវាឥណទាន, https://www.acledabank.com.kh/kh/khm/ps_credit, (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ២០២០)

23 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ផលិតផល និងសេវា, https://www.acledabank.com.kh/kh/khm/product, (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ២០២០)

ខាងក្រោម ៖

- សេវាផ្ទេរប្រាក់ក្នុងស្រុក
- សេវាផ្ទេរប្រាក់ក្រៅប្រទេសតាមរយៈប្រព័ន្ធ SWIFT
- សេវាផ្ទេរប្រាក់ក្រៅប្រទេសតាមរយៈ វ៉េសស្ទើន យូញៀន
- សេវាផ្ទេរប្រាក់ពីក្រៅប្រទេសតាមរយៈ Payone និងធនាគារ Hana (សម្រាប់ពលករខ្មែរ ដែលបម្រើការងារនៅសាធារណរដ្ឋកូរ៉េ)
- សេវាផ្ទេរប្រាក់ពីប្រទេសជប៉ុន និងសាធារណរដ្ឋកូរ៉េ[24]។

### ២.៧.៥. សេវាចាត់ចែងសាច់ប្រាក់

មានរឿងជាច្រើនដែលពាក់ព័ន្ធនឹងចរាចរសាច់ប្រាក់របស់ នីតិជន និងនីតិបុគ្គល ដែលរឿងទាំងនោះជាឧទាហរណ៍រួមមាន ការចំណាយក្នុងថ្លៃដើមដើម្បីដំណើរការអាជីវកម្ម ការបង្វិលទុន ការបង់ថ្លៃចំណាយផ្សេងៗ ការប្រមូលប្រាក់ចំណូល ឬការបើកប្រាក់ខែដល់បុគ្គលិកជាដើម។ ដើម្បីជួយសម្រួលនូវផលលំបាកទាំងអស់នេះ ធនាគារ អេស៊ីលីដា បានប្រើប្រាស់ប្រព័ន្ធដែលមានទំនាក់ទំនងប្រតិបត្តិការជាប្រចាំ ដើម្បីបង្កើតនូវបណ្តុំសេវាចាត់ចែងសាច់ប្រាក់ ដែលសមស្របទៅនឹង សេចក្តីត្រូវការផ្នែកជំនួញ និងធ្វើឱ្យលំហូរសាច់ប្រាក់របស់អតិថិជន ដំណើរការទៅយ៉ាងរលូត។

ធនាគារអេស៊ីលីដាមានបម្រើជូនសេវាចាត់ចែងសាច់ប្រាក់ជាច្រើន គួយ៉ាងមានដូចជា៖

- សេវាលិខិតអះអាងលើគណនី និងព័ត៌មានអតិថិជន
- សេវាមូលប្បទានបត្រសាច់ប្រាក់
- សេវាបើកប្រាក់បៀវត្ស
- សេវាប្រមូលសាច់ប្រាក់
- សេវាទូទាត់ឱ្យអ្នកផ្គត់ផ្គង់
- សេវាសម្រួលគណនីអតិថិជន
- សេវាបញ្ជាអចិន្ត្រៃយ៍
- សេវាទិញមូលប្បទានបត្រទេសចរណ៍
- សេវាទិញមូលប្បទានបត្របរទេស

24 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ផលិតផល និងសេវា - សេវាផ្ទេរប្រាក់, https://www.acledabank.com.kh/kh/khm/ps_fundtransfer, (ចូល ទស្សនាថ្ងៃទី ១៦ មិថុនា ២០២០)

- សេវាមូលប្បទានប័ណ្ណ
- សេវាបញ្ញើតាមរយៈប្រអប់សុវត្ថិភាព
- សេវាប្រមូលប្រាក់បង់ពន្ធ
- សេវាប្រមូលប្រាក់បង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- សេវាប្រមូលប្រាក់បង់ពន្ធលើអចលនទ្រព្យ
- សេវាទូទាត់វិក្កយបត្រនៅតាមបញ្ជរសាខាធនាគារអេស៊ីលីដា
- សេវាកិច្ចសន្យាប្តូររូបិយប័ណ្ណទុកមុន
- សេវាផ្ទេរប្រាក់ទូទាត់ជាកញ្ចប់
- សេវាប្តូរប្រាក់[25]។

**២.៧.៦. សេវាផ្សេងៗទៀត**

ក្រៅពីផលិតផល និងសេវាដ៏សំបូរបែបដែលត្រូវបានរៀបរាប់ខាងលើហើយ ធនាគារមានសេវាកម្មជាច្រើនទៀត។ សេវាកម្មទាំងនោះរួមមាន៖

- សេវាហិរញ្ញប្បទានពាណិជ្ជកម្ម (Trade Finance)
- សេវាភតិសន្យាហិរញ្ញវត្ថុ (Financial Lease)
- សេវាធានារ៉ាប់រងអាយុជីវិត ក្នុងនាមជាអ្នកណែនាំអតិថិជន (Referral Support Life Assurance Service)
- សេវាពិនិត្យសុខភាពហិរញ្ញវត្ថុ (Financial Health Check)[26]។

25 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ផលិតផល និងសេវា - សេវាចាត់ចែងសាច់ប្រាក់, https://www.acledabank.com.kh/kh/khm/ps_cashmanagement, (ចូល ទស្សនាថ្ងៃទី ១៦ មិថុនា ២០២០)

26 ធនាគារ អេស៊ីលីដា ភីអិលស៊ី, ផលិតផល និងសេវា, https://www.acledabank.com.kh/kh/khm/product, (ចូល ទស្សនាថ្ងៃទី ១៦ មិថុនា ២០២០)

# ជំពូកទី៣៖

# ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា

# ជំពូកទី៣៖ ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា

ក្នុងឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលរបស់ធនាគារបានលើកសំណើដើម្បីឲ្យអេស៊ីលីដាធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO)។ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ធនាគារបានទទួលលិខិតពីធនាគារជាតិនៃកម្ពុជា ដែល អនុញ្ញាតឲ្យបន្តគម្រោង IPO របស់ខ្លួន។ ការប្រកាសជាសាធារណៈស្តីពី IPOត្រូវបានធ្វើឡើងដោយធនាគារនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩។

នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ធនាគារ បានទទួលការយល់ព្រមជាគោលការណ៍ពីផ្សារមូលបត្រកម្ពុជា (ផ.ម.ក) លើការចុះបញ្ជីមូលបត្រកម្មសិទ្ធិរបស់ធនាគារនៅលើទីផ្សារមូលបត្រ និងបានទទួលការផ្តល់ការអនុញ្ញាត និងចុះបញ្ជី ជាគោលការណ៍លើឯកសារផ្តល់ព័ត៌មាន ដើម្បីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) លើការដាក់បង្ហាញឯកសារផ្តល់ព័ត៌មាន IPO នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០។[27]

ធនាគារបានរៀបចំការធ្វើប៊ុកបៀលឌីងចាប់ពីថ្ងៃទី ០៣ មីនា ២០២០ ដល់ ១៤ មីនា ២០២០។ បន្ទាប់មកដំណើរការធ្វើបរិវិសកម្មត្រូវបានប្រព្រឹត្តធ្វើឡើងចាប់ពីថ្ងៃ ២៤ មីនា ២០២០ ដល់ ២៤ មេសា ២០២០។ នាថ្ងៃ ទី២៥ ឧសភា ២០២០ ធនាគារអេស៊ីលីដាបានចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជាជាផ្លូវការ។

នៅក្នុងជំពូកនេះ យើងនឹងក្រឡេកទៅមើលអំពី ក្រុមហ៊ុននានាដែលពាក់ព័ន្ធនឹងការបោះផ្សាយ IPO ក្នុងដំណើរការចុះបញ្ជីនេះ ព័ត៌មានហិរញ្ញវត្ថុរបស់ធនាគារ និងព័ត៌មានទាក់ទិននឹងមូលបត្រកម្មសិទ្ធិ។ យើងក៏នឹងសិក្សាអំពី ការបង្ហាញពីសិទ្ធិរបស់ភាគហ៊ុនិក គោលនយោបាយប្រើប្រាស់មូលនិធិបានមកពីការបោះផ្សាយមូលបត្រ ដំណើរការធ្វើប៊ុកបៀលឌីង ដំណើរការធ្វើបរិវិសកម្ម និងឥទ្ធិពលរបស់ភាគហ៊ុនអេស៊ីលីដាក្នុងផ្សារមូលបត្រកម្ពុជាផងដែរ។

## ៣.១. ព័ត៌មានក្រុមហ៊ុនពាក់ព័ន្ធនឹងការបោះផ្សាយ IPO

ដើម្បីធ្វើការបោះផ្សាយមូលបត្រជាលើកដំបូង ធនាគារអេស៊ីលីដាមិនអាចអនុវត្តនីតិវិធីនានាក្នុងការបោះផ្សាយមូលបត្រតែម្នាក់ឯងនោះទេ។ យោងតាមយន្តការណែនាំស្តីពីការបោះផ្សាយមូលបត្រសាធារណៈជាលើកដំបូងចេញផ្សាយដោយ គ.ម.ក. ធនាគារអេស៊ីលីដាត្រូវបង្កើត ក្រុមការងារបោះផ្សាយលក់មូលបត្រ

27 ធនាគារអេស៊ីលីដា, របាយការណ៍ប្រចាំឆ្នាំ២០១៩, https://www.acledabank.com.kh/kh/assets/pdf_zip/ACLEDA_AnnRept2019_large_kh.zip, (ចូលទស្សនាថ្ងៃទី ០៤ សីហា ២០២០

កម្មសិទ្ធិសាធារណៈលើកដំបូងដែលរួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ជាដើម។ ក្រុមហ៊ុនទាំងនេះត្រូវតែមានការទទួលស្គាល់ពី គ.ម.ក. ផងដែរ។

ក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលស្គាល់ដោយ គ.ម.ក. មានចំនួន ៦ ក្នុងនោះមាន (១)យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (២) អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក (៣) កាណា ស៊ីឃ្យូរីធី អិលធីឌី (៤) កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (៥) អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី និង (៦)ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី។

ចំណែកឯក្រុមហ៊ុនផ្តល់សេវាសវនកម្មទទួលស្គាល់ដោយ គ.ម.ក. មានដូចជា (១) ក្រុមហ៊ុន ប្រាយ-វ៉តធ័រ ហាវខូភើស៍ (ខេមបូឌា) (២) ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា (៣) ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមី-ធីត (៤) ក្រុមហ៊ុន អឺនស្ទ អ៊ែន យ៉ាំង (ខេមបូឌា) (៥) ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត (៦) ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក (៧) ក្រុមហ៊ុន ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី និង(៨) ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក។

ចំណែកក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់មានអាជ្ញាបណ្ណពី គ.ម.ក. មានដូចជា (១) ក្រុមហ៊ុនមេធាវី អេច ប៊ី អេស (២) ការិយាល័យមេធាវី អ អេន ធី សុខ អេន ហេង (៣) ការិយាល័យមេធាវី សុក ស៊ីផាន់ណា និងសហការីជាសមាជិក ZICOlaw (៤) ការិយាល័យមេធាវី សិទ្ធិស័ក្តិ (៥) ក្រុមមេធាវី អាស៊ី កម្ពុជា (៦) ការិយាល័យមេធាវី ប៊ុន និង សហការី (៧) ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី (៨) ការិយាល័យមេធាវី ស៊ី អេស អែល និងសហភាតា (៩) ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន (១០) ការិយាល័យមេធាវី ស៊ិន & ជាតនើ (១១) ក្រុមមេធាវី កម្ពុជាបាយ័ន (ស៊ី ប៊ី អិល) (១២) ក្រុមមេធាវី មេគង្គ (១៣) ក្រុមមេធាវី កម្ពុជាសហប្រតិបត្តិការអន្តរជាតិ (១៤) ក្រុមមេធាវី ស៊ី អេស ភី និង សហការី។[28]

ក្រុមហ៊ុនដែលធនាគារអេស៊ីលីដាបានជ្រើសរើសក្នុងក្រុមការងារបោះផ្សាយមូលបត្រជាលើកដំបូងមានដូចជា៖

- ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (ក្រុមហ៊ុនធានាទិញមូលបត្រ)
- ការិយាល័យមេធាវី សិទ្ធិស័ក្តិ (ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់)
- ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា (ក្រុមហ៊ុនផ្តល់សេវាសវនកម្ម)

ខាងក្រោមនេះ ជាតារាងព័ត៌មាននៃក្រុមហ៊ុនដែលពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិ នៃធនាគារអេស៊ីលីដា។

28 គណៈកម្មការមូលបត្រកម្ពុជា, អ្នកចូលរួមទីផ្សារ, http://www.secc.gov.kh/khmer/m58.php?pn=6, (ចូលទស្សនាថ្ងៃទី ០៤ សីហា ២០២០)

**តារាងទី៣៖** ព័ត៌មានទូទៅអំពីក្រុមហ៊ុនបោះផ្សាយមូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| អាសយដ្ឋាន | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | +៨៥៥ ០២៣ ៩៩៨ ៧៧៧; +៨៥៥ ០២៣ ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ ០២៣ ៤៣០ ៥៥៥ |
| ប្រអប់សំបុត្រ | ១១៤៩ |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| គេហទំព័រ | https://www.acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ |
| លេខអាជ្ញាបណ្ណពីធនាគារជាតិ | ០៦ |

**តារាងទី៤៖** ព័ត៌មានទូទៅអំពីក្រុមហ៊ុនធានាទិញមូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |
| អាសយដ្ឋាន | អគារ Emerald ជាន់ទី៤ លេខ ៦៤ (កែងផ្លូវ ១៧៨) មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | +៨៥៥ ០២៣ ៨៦០ ៨០០ |
| លេខទូរសារ | +៨៥៥ ០២៣ ២២៤ ១២៦ |

| | |
|---|---|
| អ៊ីម៉ែល | yuanta@yuantacambodia.com |
| គេហទំព័រ | https://www.yantacambodia.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៤៥៥២ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០០៧ គ.ម.ក./ក.ត |

**តារាងទី៥៖** ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ការិយាល័យមេធាវី សិទ្ធិស័ក្តិ |
| ឈ្មោះមេធាវីតំណាង | ១. លោក សុន សុខគេង<br>២. លោក តាន់ ម៉េងស្រួយ<br>៣. លោកស្រី ម៉េង ម៉ាណែត |
| អាសយដ្ឋាន | អគារ Millennium លេខ៦៨ ជាន់ទី ៣ ផ្លូវ ៥៧<br>សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | +៨៥៥ ០២៣ ៦៣៧៣ ១៦៨ |
| អ៊ីមែល | sokeng.son@sithisak-lawoffice.com |
| គេហទំព័រ | https://www.sithisak-lawoffice.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីចេញដោយគណៈមេធាវីកម្ពុជា | L០០៧៨/១៩ |
| លេខចុះបញ្ជីទទួលស្គាល់ពីគ.ម.ក. | ០០៣ គ.ម.ក កា.ម |

**តារាងទី៦៖** ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាផ្នែកសវនកម្ម

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា (KPMG) |
| ឈ្មោះសវនករឯករាជ្យ | លោក ង៉េត ហ៊ុយ |
| អាសយដ្ឋាន | ប្រអប់សំបុត្រ ២៣៥២ អគារ Delana ជាន់ទី៤ លេខ ១៤៤ ផ្លូវ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | +៨៥៥ ០២៣ ២១៦ ៨៩៩ |
| លេខទូរសារ | +៨៥៥ ០២៣ ២១៧ ២៧៩ |
| អ៊ីមែល | kpmg@kpmg.com.kh |
| គេហទំព័រ | htttps://www.kpmg.com.kh |
| លេខចុះបញ្ជីជាសមាជិក វ.គ.ស.ក | I-0000៥ |
| លេខចុះបញ្ជីទទួលស្គាល់ពី គ.ម.ក | ០០៨គ.ម.ក/ស.ង |

## ៣.២. ការបង្ហាញព័ត៌មានហិរញ្ញវត្ថុរបស់ធនាគារ

ដើម្បីចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជាបាន ក្រុមហ៊ុនត្រូវតែបង្ហាញជាសាធារណៈនៃព័ត៌មានហិរញ្ញវត្ថុជាប្រចាំដើម្បីឲ្យមហាជន និងវិនិយោគិនសិក្សា និងវិភាគមុនធ្វើការវិនិយោគ។ ខាងក្រោមនេះជាតារាងតុល្យការ និងតារាងរបាយការណ៍លទ្ធផលរួមរបស់ធនាគារអេស៊ីលីដា

**តារាងទី៧៖** តារាងតុល្យការរួមរបស់ធនាគារអេស៊ីលីដា

| ឯកតាគិតជាដុល្លារអាមេរិក | ២០១៧ | ២០១៨ | ៣០ កញ្ញា ២០១៩ |
|---|---|---|---|
| ទ្រព្យសកម្ម | | | |
| សាច់ប្រាក់ក្នុងដៃ | ៣២១,៧៤៤,២៤៥ | ៤០៧,៨៦៤,៧០៣ | ៤២៧,៦៨៨,៧០៨ |

| | | | |
|---|---|---|---|
| សមតុល្យនៅធនាគារកណ្តាល | ១,៤៩៧,១៣៣,៣២៤ | ១,៤៧០,៥៩២,៥១៤ | ១,៧៣៣,៦៣១,០៧៧ |
| សមតុល្យនៅធនាគារផ្សេងៗ | ១២០,២៥៤,៩១៧ | ២៦,៥៦៧,៦៩២ | ១៣៤,៩៦៤,៨៣២ |
| ឥណទាន និងបុរេប្រទានអតិថិជន | ៣,០៨៥,២១៤,៦៥១ | ៣,៥១៣,៥៩៣,៨១៤ | ៣,៦៥៩,២៦៤,៥៩៤ |
| ទ្រព្យសកម្មផ្សេងៗ | ៤៩,៥៦៩,៧៧៩ | ៥១,៣៥១,៤០២ | ៥១,១៤៩,៨២២ |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | ៣០៧,១៥៩ | ២៤៨,៨៨០ | ២៤៤,១៤១ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១៣៣,៣២៨,២៨៧ | ១៣៧,៨៦២,០៩៧ | ១៣៣,២៧៦,២៧៧ |
| ទ្រព្យសកម្មអរូបី | ១១,៣៤០,៣៨៥ | ១១,១៩៧,៨៨៧ | ៩,១០៥,០៨០ |
| ពន្ធពន្យារទ្រព្យសកម្ម | ២៥,៣២១,០២៤ | ២១,៩៣៩,៩១៧ | ២៣,១១៨,៨៣១ |
| ការវិនិយោគផ្សេងៗ | ១៥៣,៥២៩ | ១៥៣,៥២៩ | ១៥៣,៥២៩ |
| ទ្រព្យសកម្មសរុប | ៥,២៤៤,៣៦៧,២៦០ | ៥,៦៤១,៣៧២,៤៣៦ | ៦,១៧២,៥៩៦,៨៩១ |
| | | | |
| បំណុល និងមូលធន<br>បំណុល | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេង | ២១២,៤៥៥,០៨៩ | ២៨៦,៩៤១,៣០៩ | ២៩៤,០៣៥,២១៨ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៣,១១៧,២០៩,៧២៦ | ៣,៥៤៨,៨៨៩,០៤០ | ៤,០៤៩,៥៨១,៥១៥ |
| សំវិធានធនកិច្ចកិច្ចសន្យាក្រៅតារាងតុល្យការ | ១,៨១៤,៦២០ | ១,៦៦៦,១៤៧ | ១,៥៤១,៦៧២ |
| បំណុលផ្សេងៗ | ៨៦,០៩៧,៣៤២ | ១០៣,៩៦៣,៧០៤ | ១១៨,៥៤០,៣៨២ |
| ប្រាក់កម្ចី | ៩០៦,៣៧៨,១៨២ | ៧៨៤,៦៧១,៨៧៩ | ៧១២,៦៧៣,០៩៩ |

| | | | |
|---|---|---|---|
| បំណុលបន្ទាប់បន្សំ | ១០៨,៦៨៤,០៩០ | ៧៧,១០១,៤៩០ | ៦៤,៦០១,៤៩០ |
| បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា | ២៣,៩៧១,៦០៥ | ១៣,៨១០,៩៩៧, | ២៣,២០៦,១៣៥ |
| អត្ថប្រយោជន៍បុគ្គលិក | ៤៧,៥៤១,២៨៤ | ១៧,៩៥២,៥០៥ | ១៨,០៧៣,១៩៩ |
| បំណុលសរុប | ៤,៥០៤,១៥១,៩៣៨ | ៤,៨៣៤,៩៩៧,០៧១ | ៥,២៨២,២៧០,៧១០ |
| | | | |
| មូលធន | | | |
| ដើមទុន | ៣៥៨,៥៤៤,៩៥៦ | ៣៩៥,២២៤,១០៥ | ៤២៨,៨១៨,១៥៤ |
| ទុនបម្រុងទូទៅ | ៣០២,១៤៨,៤១០ | ៣៤៨,១៦២,៨០៦ | ៣៩០,១៥៩,៧៥២ |
| ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ | (២,៥១២,៤៩៩) | (៦,៧៤១,៤៧០) | (៧,៩៣៩,៩៦៦) |
| ទុនបម្រុងផ្សេងៗ | (១៤,១៣២,០០៧) | (១៤,២៧៩,៣៤៤) | (១៤,២៧៩,៣៤៤) |
| ចំណេញរក្សាទុក | ៩១,៦៨៤,៥០៤ | ៨៤,០០៩,២៦៨ | ៩៣,៥៦៧,៥៨៥ |
| | ៧៣៥,៧៣៣,៣៦៤ | ៨០៦,៣៧៥,៣៦៥ | ៨៩០,៣២៦,១៨១ |
| អប្បភាគភាគកម្ម | ៤,៤៨១,៩៥៨ | - | - |
| មូលធនសរុប | ៧៤០,២១៥,៣២២ | ៨០៦,៣៧៥,៣៦៥ | ៨៩០,៣២៦,១៨១ |
| បំណុល និងមូលធនសរុប | ៥,២៤៤,៣៦៧,២៦០ | ៥,៦៤១,៣៧២,៤៣៦ | ៦,១៧២,៥៩៦,៨៩១ |

**តារាងទី៨៖** របាយការណ៍លទ្ធផលរួមរបស់ធនាគារអេស៊ីលីដា

| ឯកតាគិតជាដុល្លារអាមេរិក | ២០១៧ | ២០១៨ | ៣០ កញ្ញា ២០១៩ |
|---|---|---|---|
| ចំណូលការប្រាក់ | ៤២៥,៣៤៥,៦២៩ | ៤២៣,២៥៦,១៨៤ | ៣៤១,៣៤៦,៣៣៣ |
| ចំណាយការប្រាក់ | (១៤៩,៦៤១,២៦០) | (១៥១,៤០៤,៦៨២) | (១១៦,១០០,២២០) |
| ចំណូលការប្រាក់សុទ្ធ | ២៧៥,៧០៤,៣៦៩ | ២៧១,៨៥១,៥០២ | ២២៥,២៤៦,១១២ |
| | | | |
| ចំណូលកម្រៃ និងជើងសា | ៥៨,៨៦២,០១៩ | ៦៤,៤១៣,៤១៨ | ៥៤,០១០,៦៥៣ |
| ចំណាយកម្រៃ និងជើងសា | (២,៨៦៧,០៦១) | (៧៤៩,៥០១) | (៥៤៨,៧៩៣) |
| ចំណូលកម្រៃ និងជើងសាសុទ្ធ | ៥៥,៩៩៤,៩៥៨ | ៦៣,៦៦៣,៩១៧ | ៥៣,៤៦១,៨៦០ |
| | | | |
| សំវិធានធនឥណទានបាត់បង់ និងសមតុល្យនៅធនាគារផ្សេងៗ | (៣៤,២៥០,៣២៤) | (៤០,៧១១,១១០) | (៩,៧០៧,១៥០) |
| សំវិធានធនកិច្ចសន្យាក្រៅតារាងតុល្យការ | (១,៨១៤,៦២០) | (១៤២,២៤៨) | (១៣១,០២៩) |
| សំវិធានធនឥណទានបាត់បង់ សមតុល្យនៅធនាគារផ្សេងៗ និងកិច្ចសន្យាក្រៅតារាងតុល្យការ-សុទ្ធ | (៣៦,០៦៤,៩៤៤) | (៤០,៥៦៨,៨៦២) | (៩,៨៧៦,១២១) |
| | | | |
| ចំណូលបន្ទាប់ពីកាត់កងសំវិធានធនសុទ្ធ | ២៩៥,៦៣៤,៣៨៣ | ២៩៤,៩៤៦,៥៥៧ | ២៦៩,១៣១,៨៥១ |

| | | | |
|---|---|---|---|
| ចំណូលផ្សេងៗ | ១០,៦០១,៨២៤ | ១៤,៩៣៣,៩១៦ | ១២,៥៤៥,៤៩០ |
| ចំណូលសរុប | ៣០៦,២៣៦,២០៧ | ៣០៩,៨៨០,៤៧៣ | ២៨១,៦៧៧,៣៤១ |
| | | | |
| ចំណាយបុគ្គលិក | (១១២,២៣៨,៨៦៩) | (១២៥,៩២២,២៣១) | (១០៤,៤១០,៧២៧) |
| ជំណាយទូទៅ និងចំណាយរដ្ឋបាល | (៥២,៣០៨,៧៣៦) | (៥១,៨៦៥,៦៥៨) | (៣៩,៧៣៤,២៦០) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និង បរិក្ខារ | (២១,២៦៥,២២៦) | (២១,៩៣៤,៨៤៨) | (១៦,០០៥,១០៤) |
| ចំណាយរំលស់ទ្រព្យសកម្មអរូបី | (៤,០៥១,០៨៤) | (៣,៥៥០,០៥៥) | (២,៦៩៦,៣០៨) |
| ចំណាយសរុប | (១៨៩,៨៦៣,៩១៥) | (២០៣,២៧២,៧៩២) | (១៦២,៨៤៦,៣៩៩) |
| | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | ១១៦,៣៧២,២៩២ | ១០៦,៦០៧,៦៨១ | ១១៨,៨៣០,៩៤២ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (២៣,៨៤៤,២៩៤) | (២២,៥៩៨,៤១៣) | (២៥,២៦៣,៣៥៧) |
| ចំណេញក្នុងគ្រា | ៩២,៥២៧,៩៩៨ | ៨៤,០០៩,២៦៨ | ៩៣,៥៦៧,៥៨៥ |
| ត្រូវបែងចែកជូន៖ | | | |
| ម្ចាស់ភាគហ៊ុនរបស់ធនាគារ | ៩១,៦៨៤,៥០៤ | ៨៤,០០៩,២៦៨ | ៩៣,៥៦៧,៥៨៥ |
| អប្បភាគភាគកម្ម | ៨៤៣,៤៩៤ | - | - |
| | ៩២,៥២៧,៩៩៨ | ៨៤,០០៩,២៦៨ | ៩៣,៥៦៧,៥៨៥ |

## ៣.៣. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិចេញផ្សាយដំបូង (IPO)

### ៣.៣.១. ព័ត៌មានអំពីការដាក់សំណើការផ្សាយលក់មូលបត្រកម្មសិទ្ធិ

យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលកាលពីថ្ងៃទី ២១-២២ ខែមីនា ឆ្នាំ២០១៩ ក្រុម-ប្រឹក្សាភិបាលបានសម្រេចអនុម័ត និងស្នើទៅកាន់ភាគហ៊ុនិកសម្រាប់ការអនុម័តជាចុងក្រោយលើការបោះ-ផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទាំងមូលបត្រកម្មសិទ្ធិថ្មី និងមូលបត្រកម្មសិទ្ធិដែលកំពុងកាន់កាប់ មិនលើសពី ២០% នៃចំនួនមូលបត្រកម្មសិទ្ធិសរុបរបស់ធនាគារ ដើម្បីចុះបញ្ជីលក់មូលបត្រនៅក្រុមហ៊ុនផ្សារ

មូលបត្រកម្ពុជា។

ធនាគារ អេស៊ីលីដា និងភាគហ៊ុនិករបស់ធនាគារ បានសម្រេចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីចំនួន ២% ដែលស្មើនឹង ៨,៧៥១,៣៩១ ភាគហ៊ុន និងមូលបត្រកម្មសិទ្ធិបច្ចុប្បន្នរហូតដល់ ៣% ដែលស្មើនឹង ១៣,១២៧,០៨៦ ភាគហ៊ុន ផ្អែកតាមលទ្ធផល នៃប៊ុកបៀលឌីង និង បរិវិសកម្ម។

**តារាងទី៩៖** លក្ខខណ្ឌនៃសំណើលក់មូលបត្រ

| | |
|---|---|
| ប្រភេទមូលបត្រកម្មសិទ្ធិ | មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៤,000 រៀល (១.00 ដុល្លារអាមេរិក) |
| ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ១៦,២០០ រៀល |
| ចំនួនមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ | ៨,៧៥១,៣៩១ ភាគហ៊ុន |
| ចំនួនមូលបត្រកម្មសិទ្ធិបច្ចុប្បន្នដែលធ្វើសំណើលក់ | រហូតដល់ ១៣,១២២៧,០៨៦ ភាគហ៊ុន អាស្រ័យលើការសម្រេចចិត្តរបស់ភាគហ៊ុនិក ផ្អែកតាមលទ្ធផលនៃការធ្វើ នៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម |
| កាលបរិច្ឆេទការធ្វើប៊ុកបៀលឌីង | ០៣/មីនា/២០២០ ដល់ ១៤/មីនា/២០២០ |
| ការបរិច្ឆេទការធ្វើបរិវិសកម្ម | ២៤/មីនា/២០២០ ដល់ ២៤/មេសា/២០២០ |
| ទីកន្លែងនៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម | សាខាអេស៊ីលីដានិងក្រុមហ៊ុនស៊ីយូរីធី មួយចំនួន |

### ៣.៣.២. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ដោយធនាគារ ត្រូវបានបែងចែកទៅឲ្យវិនិយោគិនជាពីរដំណាក់កាល គឺដំណាក់កាលនៃការធ្វើប៊ុកបៀលឌីង និងដំណាក់កាលនៃការធ្វើបរិសកម្ម។ ខាងក្រោមជាតារាងផែនការបែងចែកមូលបត្រ។

**តារាងទី១០៖** ផែនការបែងចែកមូលបត្រ

| | ចំនួនមូលបត្រធ្វើការបែងចែក | ប្រភេទ |
|---|---|---|
| ការធ្វើប៊ុកបៀលឌីង | ៤,៣៧៥,៦៩៦ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោត |
| ការធ្វើបរិសកម្ម | ពី ៤,៣៧៥,៦៩៥<br>ទៅ ១៧,៥០២,៧៨១ | មូលបត្រកម្មសិទ្ធិមានសិទ្ធបោះឆ្នោត |
| សរុប | យ៉ាងតិច ៨,៧៥១,៣៩១ | |

### ៣.៣.៣. តម្លៃមួយឯកតានៃមូលបត្រកម្មសិទ្ធិ

តម្លៃមូលបត្រកម្មសិទ្ធិពី ១៥,០០០ រៀល ទៅ ១៧,៤០០ រៀល (៣.៧៥ដុល្លារអាមេរិកទៅ៤.៣៥ ដុល្លារអាមេរិក) ដែលបានដាក់ឱ្យវិនិយោគិនធ្វើការកំណត់ថ្លៃក្នុងវគ្គប៊ុកបៀលឌីង គឺផ្អែកលើការវាយតម្លៃដោយប្រៀបធៀប (Relative Valuation) ជាមួយក្រុមហ៊ុនដែលស្រដៀងគ្នាក្នុងអាជីវកម្មធនាគារក្នុងតំបន់។

ក្រុមហ៊ុនធានាទិញមូលបត្រជឿជាក់ថា ការវាយតម្លៃធនាគារ អេស៊ីលីដា ដោយប្រើវិធីសាស្ត្រវាយតម្លៃដោយប្រៀបធៀប (Relative Valuation) គឺមានលក្ខណៈសមស្របជាងការប្រើវិធីសាស្ត្រវាយតម្លៃដាច់ខាត (Absolute Model) ឬ វិធីសាស្ត្រលំហូរសាច់ប្រាក់អប្បហារ (Discounted Cash Flow Model) ដែលតម្រូវឱ្យ មានការប៉ាន់ស្មានទាំងលំហូរសាច់ប្រាក់ និងអត្រាអប្បហារ។ ព័ត៌មាន សំខាន់ៗសម្រាប់ប៉ាន់ស្មានថ្លៃដើមនៃ មូលធន (Cost of Equity) ដូចជាការប្រែប្រួលនៃបេតា (Beta) អត្រាសំណងលើហានិភ័យមូលធន (Equity Risk Premium) និងអត្រាសំណងគ្មានហានិភ័យ (Risk Free Rate) មិនមានស្រាប់នោះទេនៅប្រទេសកម្ពុជា ដោយសារគ្មានការជួញដូរមូលបត្ររដ្ឋ ហើយទីផ្សារមូលធនទើបតែចាប់ផ្ដើមនៅឡើយ។ ដូច្នេះ ការប្រើវិធីសាស្ត្រវាយតម្លៃដាច់ខាត នឹងមានការសន្មតជាច្រើនដែលធ្វើឱ្យការវាយតម្លៃជារួមមិនអាចប្រើប្រាស់បានបើធៀបទៅនឹងវិធីសាស្ត្រវាយតម្លៃដោយប្រៀបធៀប។

តម្លៃក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់គឺស្មើនឹង ១៦,២០០ រៀល។ ធនាគារ អេស៊ី-លីដា និងក្រុមហ៊ុនធានាទិញមូលបត្របានកំណត់ថ្លៃចុងក្រោយ ដោយផ្អែកលើនីតិវិធី នៃការធ្វើប៊ុកបៀល-ឌីង និងការធ្វើបរិវិសកម្ម។ តម្លៃចុងក្រោយនេះត្រូវបានអនុម័តដោយ ផ.ម.ក. និង គ.ម.ក.។

### ៣.៣.៤. សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រ

តាមរយៈការបោះផ្សាយមូលបត្រកម្មសិទ្ធិថ្មីចំនួន ៨,៧៥១,៣៩១ ភាគហ៊ុន (មានសិទ្ធិបោះឆ្នោត) ដែលមានតម្លៃស្មើនឹង ១៦,២០០ រៀល ធនាគារអេស៊ីលីដា នឹងទទួលបានសាច់ប្រាក់សុទ្ធពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈចំនួនប្រហែល ១៣៧.៨ ពាន់លានរៀល (ប្រហែល ៣៤.៤៥ លាន ដុល្លារអាមេរិក)។

ធនាគារអេស៊ីលីដា មានបំណងប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយនេះសម្រាប់គោលបំណងសាជីវកម្មទូទៅ។

## ៣.៤. សិទ្ធិរបស់ភាគហ៊ុនិក

**ការទិញភាគហ៊ុនត្រលប់ដោយក្រុមហ៊ុន**

ធនាគារអាចទិញភាគហ៊ុនរបស់ខ្លួនត្រលប់មកវិញ ដោយត្រូវមានការយល់ព្រមជាមុនដោយសំឡេងឆ្នោតគាំទ្រយ៉ាងតិចចំនួន២/៣ នៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងដោយសំឡេងឆ្នោតគាំទ្ររបស់ភាគ-ហ៊ុនិកភាគច្រើន ២/៣ នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតសរុប ព្រមទាំងត្រូវអនុលោមតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិក**

មហាសន្និបាតភាគហ៊ុនិក ត្រូវធ្វើឡើងនៅទីស្នាក់ការកណ្តាល ឬនៅទីកន្លែងផ្សេងទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកដែលជាអ្នកកោះប្រជុំ។

**ការជូនដំណឹងអំពីមហាសន្និបាតភាគហ៊ុនិក**

ប្រធានក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាភិបាល ត្រូវជូនដំណឹងអំពីមហាសន្និបាតភាគហ៊ុនិកតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយអេឡិចត្រូនិកដល់ភាគហ៊ុនិកទាំងអស់ដែលមានសិទ្ធិក្នុងការចូលរួមមហាសន្និបាតភាគហ៊ុនិកឱ្យបានយ៉ាងតិច ២០ថ្ងៃ ប៉ុន្តែមិនឱ្យលើសពី ៥០ ថ្ងៃ មុនកាលបរិច្ឆេទមហាសន្និបាតឡើយ។ ការជូនដំណឹងនោះ ត្រូវបញ្ជាក់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងមហាសន្និបាត ព្រមទាំងរបៀបវារៈដែលត្រូវពិភាក្សា និងសម្រេចផងដែរ។

**ការកែប្រែរបៀបវារៈមហាសន្និបាតភាគហ៊ុនិក**

ភាគហ៊ុនិកចូលរួមមហាសន្និបាតដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកដែលកាន់កាប់ភាគហ៊ុន យ៉ាងហោចណាស់ ៧៥% (ចិតសិបប្រាំភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតទើបអាចកែប្រែរបៀបវារៈមហាសន្និបាតបានក្នុងពេល ឬមុនពេលមហាសន្និបាត។

**កាលបរិច្ឆេទកំណត់ទុក**

សម្រាប់គោលបំណងកំណត់ចំនួនភាគហ៊ុនិកដែលមានសិទ្ធិទទួលបានសេចក្តីជូនដំណឹង ឬមានសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចប្រជុំណាមួយរបស់ភាគហ៊ុនិក ឬនៅក្នុងកិច្ចប្រជុំលើកពេលណាមួយ ឬមានសិទ្ធិទទួលបាននូវការទូទាត់ភាគលាភ ឬដើម្បីកំណត់ចំនួនភាគហ៊ុនិកសម្រាប់គោលបំណងផ្សេងណាមួយ ក្រុមប្រឹក្សាភិ-បាលអាចកំណត់នូវកាលបរិច្ឆេទកំណត់ទុកសម្រាប់ការកំណត់ចំនួនភាគហ៊ុនិក ដោយមិនត្រូវលើសពី ៥០ ថ្ងៃ និងមហាសន្និបាតភាគហ៊ុនិកមិនត្រូវតិចជាង ២០ថ្ងៃ មុនចំណាត់ការធ្វើអ្វីមួយក្រោយការកំណត់កាលបរិច្ឆេទកំណត់ទុក។

ប្រសិនបើក្រុមប្រឹក្សាភិបាលមិនបានបង្កើតកាលបរិច្ឆេទកំណត់ទុក នោះកាលបរិច្ឆេទកំណត់ទុកត្រូវកំណត់នៅថ្ងៃធ្វើការចុងក្រោយ មុនពេលជូនដំណឹងអំពីកិច្ចប្រជុំ ឬប្រសិនគ្មានការជូនដំណឹងទេ ត្រូវយកថ្ងៃបើកកិច្ចប្រជុំ។

កាលបរិច្ឆេទកំណត់ទុក ដើម្បីកំណត់ចំនួនភាគហ៊ុនិកសម្រាប់បញ្ហាណាមួយក្រៅពីសិទ្ធិទទួលសេចក្តីជូនដំណឹងអំពីកិច្ចប្រជុំ ឬសិទ្ធិបោះឆ្នោត ត្រូវយកថ្ងៃធ្វើការចុងក្រោយដែលក្រុមប្រឹក្សាភិបាលអនុម័តសេចក្តីសម្រេចដែលទាក់ទងនឹងបញ្ហានោះ។

នៅពេលការកំណត់ចំនួនភាគហ៊ុនិក ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិកត្រូវបានធ្វើឡើងដូចមានចែងក្នុងមាត្រានេះ ការកំណត់នេះត្រូវអនុវត្តចំពោះការលើកពេលកិច្ចប្រជុំផងដែរ លើកលែងតែក្រុមប្រឹក្សាភិបាលបានកំណត់កាលបរិច្ឆេទកំណត់ទុកថ្មី។

**កូរ៉ុម**

កូរ៉ុមនៃមហាសន្និបាតភាគហ៊ុនិក ត្រូវតែជាភាគហ៊ុនិកចូលរួមមហាសន្និបាតដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហក ដែលកាន់កាប់ភាគហ៊ុនយ៉ាងតិច ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត។ ភាគហ៊ុនដែលតំណាងតាមរយៈអាណត្តិគាហកនឹងត្រូវរាប់បញ្ចូលដើម្បីកំណត់កូរ៉ុមនៃមហាសន្និ-បាត។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនដើម្បីធ្វើមហាសន្និបាតណាមួយនោះ មហាសន្និបាតនោះនឹងត្រូវបានគេផ្អាករយៈពេល ៣០ថ្ងៃ។ ការជូនដំណឹងអំពីការផ្អាកមហាសន្និបាត ត្រូវផ្ញើជូនគ្រប់ភាគហ៊ុនិកទាំងអស់។ នៅពេលចាប់បន្តមហាសន្និបាតដែលបានផ្អាកនោះ ភាគហ៊ុនិកទាំងអស់ដែលមានវត្តមាន ក្នុងមហាសន្និបាត

ដែលផ្អាកនោះ ជាកូរ៉ុមដែលអាចធ្វើមហាសន្និបាតបាន ។

**អាណត្តិគាហក**

ភាគហ៊ុនិក អាចផ្តល់អាណត្តិគាហកជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងណាម្នាក់ឱ្យចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក។ អាណត្តិគាហកនោះមានសុពលភាពសម្រាប់តែ មហាសន្និបាតភាគហ៊ុនិកមួយលើកប៉ុណ្ណោះ (ចំពោះមហាសន្និបាតភាគហ៊ុនិកដែលបានផ្អាកនោះ ក៏ចាត់ទុកថាជាផ្នែកដូចគ្នាមួយនៃមហាសន្និបាតភាគហ៊ុនិកនោះផងដែរ)។ អាណត្តិគាហកអាចដកហូតមកវិញបានគ្រប់ពេល ហើយត្រូវបានដកដោយស្វ័យប្រវត្តិ ប្រសិនបើភាគហ៊ុនិកដែលបានផ្តល់សិទ្ធិប្រទាននោះបានចូលរួមមហាសន្និបាតភាគ-ហ៊ុនិកដោយផ្ទាល់។ ករណីអាណត្តិគាហកចូលរួមបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក លិខិតតែងតាំងអាណត្តិគាហករូបនោះត្រូវដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុង ឬមុនពេលចាប់ផ្តើមកិច្ចប្រជុំ។

លិខិតអាណត្តិគាហកត្រូវចុះកាលបរិច្ឆេទ មានហត្ថលេខារបស់ភាគហ៊ុនិក ព្រមទាំងត្រូវបញ្ជាក់៖

១. ចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិកតាមរយៈអាណត្តិគាហក

២. ឈ្មោះ និងអាសយដ្ឋានពេញលេញរបស់អាណត្តិគាហកនោះ និង

៣. កិច្ចប្រជុំដែលអាណត្តិគាហកនោះត្រូវបានតែងតាំងឱ្យចូលរួម។

**ការរំលាយដោយស្ម័គ្រចិត្ត និងការជម្រះបញ្ជី**

ធនាគារអាចបញ្ឈប់សកម្មភាពអាជីវកម្ម និងជម្រះបញ្ជីបិទតាមការសម្រេចពិសេសរបស់ភាគហ៊ុនិកក្រោមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

១. ភាពក្ស័យធនរបស់ធនាគារ។

២. ការសម្រេចរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនយ៉ាងតិចចំនួន ៧៥% (ចិតសិបប្រាំភាគរយ) នៃ ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតសរុបទាំងអស់។

ធនាគារក៏អាចត្រូវបានរំលាយដោយការសម្រេចរបស់តុលាការ។

ក្នុងករណីជម្រះបញ្ជី ក្រុមប្រឹក្សាភិបាលត្រូវរៀបចំផែនការដើម្បីរំលាយធនាគារដែលត្រូវយកមក អនុវត្តបន្ទាប់ពីទទួលបានការអនុម័តពីភាគហ៊ុនិក។ ការរំលាយ និងការជម្រះបញ្ជីធនាគារត្រូវអនុវត្តស្របតាមនីតិវិធីដែលមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ការទូទាត់ភាគលាភ ក្រោមគោលនយោបាយភាគលាភ**

ធនាគារ និងទូទាត់ភាគលាភទៅឱ្យភាគហ៊ុនិកទាំងអស់របស់ខ្លួន អនុលោមតាមគោលនយោបាយ

ដែលពាក់ព័ន្ធទៅនឹងការប្រកាស និងការទូទាត់ភាគលាភ និងអនុម័តពីភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន ដោយសំឡេងឆ្នោតគាំទ្រយ៉ាងតិច ៥១% នៃភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតដែលបានចូលរួមការបោះ-ឆ្នោត។

**បុព្វសិទ្ធិ (សិទ្ធិទិញមុនគេ)**

ក្នុងករណីធនាគារអេស៊ីលីដា ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែម ភាគហ៊ុនិកទាំងអស់មានសិទ្ធិទិញមុនគេនូវមូលបត្រកម្មសិទ្ធិដែលបោះផ្សាយបន្ថែមនេះទៅតាមសមាមាត្រនៃចំនួន និងប្រភេទនៃមូល- បត្រកម្មសិទ្ធិដែលខ្លួនកាន់កាប់តាមតម្លៃ និងលក្ខខណ្ឌដូចគ្នាក្នុងករណីបោះផ្សាយលក់ទៅតតិយជន។ ដូចនេះ ធនាគារ អេស៊ីលីដា ត្រូវធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមនេះក្នុងលក្ខខណ្ឌដូចគ្នាសម្រាប់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិទាំងអស់ដែលមានសិទ្ធិទិញមុននេះ និងត្រូវជាភាគហ៊ុនដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិករបស់អេស៊ីលីដានៅកាលបរិច្ឆេកំណត់ទុក។

កាលបរិច្ឆេទកំណត់ទុកគឺត្រូវកំណត់នៅត្រឹមថ្ងៃបិទការជួញដូរដែលអេស៊ីលីដាជ្រើសរើស សម្រាប់បិទបញ្ជីភាគហ៊ុនិក ដើម្បីកំណត់ពីភាគហ៊ុនិកណាមានសិទ្ធិទទួលបានសិទ្ធិទិញមុននេះ។ ការបរិច្ឆទ អិចរាយ៍ (ex-right) គឺត្រូវកំណត់យកមួយថ្ងៃជួញដូរមុនកាលបរិច្ឆេទកំណត់ទុក។ ដើម្បីទទួលបានសិទ្ធិទិញមុន ភាគ-ហ៊ុនិកត្រូវទិញមូលបត្រកម្មសិទ្ធិឱ្យបានមុនកាលបរិច្ឆេទអិចរាយថ៍ (ex-right)។ ករណីមូលបត្រកម្មសិទ្ធិត្រូវបានទិញនៅ ឬបន្ទាប់ពីអិចរាយថ៍ (ex-right) នោះភាគហ៊ុនិកមុនជាអ្នកមានសិទ្ធិ។

បន្ទាប់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ធនាគារ អេស៊ីលីដាតាមរយៈសេចក្តីសម្រេចក្រុមប្រឹក្សាភិបាល និងបន្ទាប់ពីទទួលបានការអនុម័តពីភាគហ៊ុនិក អាចបោះផ្សាយមូលបត្រកម្មសិទ្ធិបន្ថែមលក់ទៅឱ្យតតិយជនក្រៅពីភាគហ៊ុនិកដែលកំពុងកាន់កាប់ភាគហ៊ុនស្រាប់ដោយមិនគិតពីសិទ្ធិទិញមុនគេ ក្នុងករណីដូចខាងក្រោម៖

- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជូនទៅនិយោជិតរបស់ធនាគារ អេស៊ីលីដា
- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដើម្បីសម្រេចគោលបំណងអាជីវកម្មពិសេស ដែលរួមមានការដាក់ឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាថ្មី ឬការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពហិរញ្ញវត្ថុ។ល។
- ការបោះផ្សាយក្នុងទម្រង់ជាបណ្ណទទួលតម្កល់មូលបត្រកម្មសិទ្ធិ (depositary receipts) ស្របទៅតាម ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**សិទ្ធិស្នើសុំធ្វើការវាយតម្លៃមូលបត្រកម្មសិទ្ធិ**

យោងតាមច្បាប់សហគ្រាសពាណិជ្ជកម្ម ក្នុងករណីមានការរំលាយក្រុមហ៊ុនបញ្ចូលគ្នាជាមួយក្រុម-ហ៊ុនមួយផ្សេងទៀត ភាគហ៊ុនិកនៃក្រុមហ៊ុនដើមមានសិទ្ធិទាមទារឱ្យមានការវាយតម្លៃលើ និងទិញមូលបត្រកម្មសិទ្ធិរបស់ខ្លួន។ ដើម្បីអនុវត្តសិទ្ធិនេះ ភាគហ៊ុនិកនោះត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- កាន់កាប់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនដើម មុនពេលអនុញ្ញាតឱ្យមានការរំលាយក្រុមហ៊ុនបញ្ចូលគ្នាតាមរយៈមហាសន្និបាតភាគហ៊ុនិក។
- មិនបានបោះឆ្នោតគាំទ្រការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- ធ្វើការទាមទារជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិកៈ
- ស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។
- ប្រគល់បណ្ណភាគហ៊ុនរបស់ខ្លួនទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តស្របពេលដែលកំពុងស្នើសុំឱ្យមានការវាយតម្លៃ។

ថ្លៃទិញមូលបត្រកម្មសិទ្ធិនេះត្រូវកំណត់តាមរយៈការចរចារគ្នារវាងភាគហ៊ុនិកនៃក្រុមហ៊ុនដើម និងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្នុងរយៈពេលមិនលើសពី ៩០ថ្ងៃ។ ករណីគ្មានការឯកភាពគ្នាលើតម្លៃសមរម្យទេនោះ តុលាការនឹងសម្រេចលើតម្លៃសមរម្យនោះ ហើយភាគហ៊ុនិកនៃក្រុមហ៊ុនដើមត្រូវទទួលយកតាមការកំណត់របស់តុលាការ។

**សិទ្ធិទទួលបានព័ត៌មាន**

សាធារណជនអាចចូលទៅកាន់គេហទំព័ររបស់ធនាគារ អេស៊ីលីដា និង ផ.ម.ក. ឬស្នើសុំទៅធនាគារដើម្បីពិនិត្យមើលឯកសារផ្ដល់ព័ត៌មានដែលបានចុះបញ្ជី ព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានពាក់ព័ន្ធនានាផ្សេងទៀត។ បន្ថែមពីនេះ បន្ទាប់ពីទទួលបានសំណើ និងការបង់ថ្លៃសមរម្យ ធនាគារត្រូវ ផ្ដល់ជូនភាគហ៊ុនិករបស់ខ្លួននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលធ្វើសវនកម្មរួច លទ្ធផលប្រតិបត្តិការ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ព័ត៌មានអំពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតអំពីក្រុមហ៊ុន ក្នុងទម្រង់បោះពុម្ព។

## ៣.៥. គោលនយោបាយភាគលាភ

ធនាគារអេស៊ីលីដាកំណត់ការបែងចែកភាគលាភឱ្យមានភាពត្រឹមត្រូវ និងមានប្រសិទ្ធភាពដល់ភាគ-ហ៊ុនិក ដោយដាក់ចេញនូវគោលនយោបាយបែងចែកភាគលាភ ដើម្បីបែងចែកភាគលាភដល់ភាគហ៊ុនិក ហើយធ្វើឱ្យមានកំណើនដើមទុនផងដែរ។ ធនាគារចាត់ថ្នាក់ភាគលាភជាបីប្រភេទដូចខាងក្រោម៖

- ភាគលាភជាសាច់ប្រាក់

- ភាគលាភជាមូលបត្រកម្មសិទ្ធិ និង
- ក្នុងទម្រង់ផ្សេងទៀតតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិកដោយស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**អនុបាតភាគលាភ**

ធនាគារកំណត់អនុបាតភាគលាភរហូតដល់ ៥០% នៃប្រាក់ចំណេញក្រោយបង់ពន្ធនៃឆ្នាំសារពើពន្ធមុន។

**លក្ខខណ្ឌនៃការបែងចែកភាគលាភ**

ភាគលាភនឹងបែងចែកជូនភាគហ៊ុនិកយ៉ាងតិចមួយដងក្នុងមួយឆ្នាំ។ ភាគលាភនឹងបែងចែកនៅពេលមានចំណេញពីប្រតិបត្តិការរបស់ធនាគារ និងត្រូវបានទទួលស្គាល់ ជាក់ស្តែងដោយសវនករឯករាជ្យ។ ភាគលាភនឹងត្រូវធ្វើការបែងចែក នឹងស្របតាមផែនការអាជីវកម្ម។ ករណី មានតម្រូវការចាំបាច់ដើម្បីរក្សាប្រាក់ចំណេញសម្រាប់គោលបំណងវិនិយោគ ឬគោលបំណងណាមួយ តាមរយៈការពិភាក្សាយ៉ាងហ្មត់ចត់ជាមួយក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា នឹងស្នើសុំការអនុញ្ញាតពី គ.ម.ក. និងផ្សព្វផ្សាយជាសាធារណៈ។

**ការប្រកាសភាគលាភ**

ភាគលាភនឹងត្រូវប្រកាសដោយសេចក្តីសម្រេចក្រុមប្រឹក្សាភិបាល ដែលមានសំឡេងឆ្នោតយ៉ាងតិច ៧៥% (ចិតសិបប្រាំភាគរយ) និងអនុម័តដោយភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច៥១%។

ការប្រកាសភាគលាភត្រូវពិចារណាពីកត្តា និងព័ត៌មានមួយចំនួន ដូចខាងក្រោម៖

- គ្មានកត្តាជាសារវ័ន្តណាមួយដែលប៉ះពាល់ដល់ប្រាក់ចំណេញក្រោយបង់ពន្ធ
- តម្រូវការសាច់ប្រាក់ ចំណេញពីប្រតិបត្តិការពេលបច្ចុប្បន្ន និងអនាគត
- តម្រូវការវិនិយោគសម្រាប់ផែនការអនាគត
- ស្ថានភាពហិរញ្ញវត្ថុ និងកិច្ចព្រមព្រៀងបំណុល
- ព័ត៌មានដែលតម្រូវដោយអាជ្ញាធរពាក់ព័ន្ធ និង
- កត្តាសេដ្ឋកិច្ចពាក់ព័ន្ធនានាដែលអាចប៉ះពាល់ដល់សម្ព័ន្ធធនាគារ អេស៊ីលីដា។

**ការទូទាត់ភាគលាភ**

ធនាគារត្រូវកំណត់ពីកាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបិទការទូទាត់ភាគលាភ។ កាលបរិច្ឆេទចាប់ផ្តើមនៃការទូទាត់ភាគលាភត្រូវចាប់ផ្តើមមិនលើសពី ៧ ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទ កំណត់ទុក។

ធនាគារត្រូវធ្វើការទូទាត់ភាគលាភជូនភាគហ៊ុនិកទាំងអស់ ដែលមានក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភនៅក្នុងរយៈពេលដូចបានកំណត់ខាងលើ។

ភាគលាភត្រូវធ្វើការទូទាត់ដូចខាងក្រោម៖

- ភាគលាភជាសាច់ប្រាក់ត្រូវធ្វើការទូទាត់បន្ទាប់ពីធនាគារទទួលបានការបញ្ជាក់ពីព័ត៌មានលេខគណនីរបស់ភាគហ៊ុនិកទាំងអស់។
- ភាគលាភជាមូលបត្រកម្មសិទ្ធិត្រូវធ្វើការទូទាត់ទៅតាមការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា បន្ទាប់ពីមហាសន្និបាតភាគហ៊ុនិក។
- ភាគហ៊ុនិកមានសិទ្ធិធ្វើការតវ៉ាករណីមិនពេញចិត្តលើការបែងចែកភាគលាភក្នុងរយៈពេល ៧ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទបិទការទូទាត់ភាគលាភ។

ធនាគារត្រូវផ្តល់របាយការណ៍ស្តីពីការទូទាត់ភាគលាភជូន គ.ម.ក. ក្នុងរយៈពេល ៣ ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការកំណត់រយៈពេលនៃការតវ៉ា។[29]

## ៣.៦. ដំណើរការធ្វើប៊ុកបៀលឌីង

ធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយមានការគាំទ្រដោយក្រុមហ៊ុនធានាទិញមូលបត្រ យាន់តា ស៊ី-ឃ្យូ-វីធី (ខេមបូឌា) ភីអិលស៊ី បានជូនដំណឹងពីការធ្វើប៊ុកបៀលឌីងដើម្បីកំណត់ថ្លៃភាគហ៊ុនរបស់ធនាគារដែលគ្រោងនឹងចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ការធ្វើប៊ុកបៀលឌីងនេះធ្វើឡើងចាប់ពីថ្ងៃ ០៣ មីនា ២០២០ ដល់ ១៤ មីនា ២០២០។ (ទម្រង់សូមធ្វើការចូលរួមធ្វើប៊ុកបៀលឌីងមាននៅក្នុងឧបសម្ព័ន្ធទី២)

### ៣.៦.១. ការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិ

ធនាគារ អេស៊ីលីដា ភីអិលស៊ី គាំទ្រដោយក្រុមហ៊ុន យាន់តា នឹងកំណត់ថ្លៃមូលបត្រកម្មសិទ្ធិ ស្របទៅតាមនីតិវិធីស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្ម ដែលទទួលបានការអនុញ្ញាតពី គណៈកម្មការមូលបត្រកម្ពុជា ("គ.ម.ក.")។ ថ្លៃមូលបត្រកម្មសិទ្ធិនឹងត្រូវប្រកាសជូន បន្ទាប់ពីទទួលបានការអនុម័ត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.។

ចន្លោះថ្លៃប៊ុកបៀលឌីង៖ ១៥.០០០ រៀល ដល់ ១៧.៤០០ រៀល។

### ៣.៦.២. ការបង្ហាញព័ត៌មានលម្អិត ( Roadshow )

ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរៀបចំកម្មវិធីបង្ហាញព័ត៌មានលម្អិត (Roadshow) ចំនួន ០២

29 ធនាគារអេស៊ីលីដា, ឯកសារផ្តល់ព័ត៌មាន, https://www.acledabank.com.kh/kh/khm/listing-disclosure-documents, (ចូលទស្សនាថ្ងៃទី ០៥ សីហា ២០២០)

លើក ដើម្បីធ្វើបទបង្ហាញដល់វិនិយោគិន អំពីទិដ្ឋភាពទូទៅនៃអាជីវកម្មហិរញ្ញវត្ថុរបស់ធនាគារ ពេលវេលារំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការរៀបចំខ្លួនរបស់វិនិយោគិន ដើម្បីមានការយល់ដឹងច្រើនជាងមុនអំពីធនាគារ មុននឹងធ្វើការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិនៅ ក្នុងដំណាក់កាលប៊ុកបៀលឌីង។ កម្មវិធីបង្ហាញព័ត៌មានលម្អិត (Roadshow) ត្រូវបានកំណត់ ដូចខាងក្រោម៖

- កម្មវិធីបង្ហាញព័ត៌មានលម្អិត (Roadshow) លើកទី១
  - កាលបរិច្ឆេទ ៖ ៣ មីនា ២០២០ ចាប់ពីម៉ោង ៣:៣០រសៀល ដល់ម៉ោង ៦:០០ល្ងាច
  - ទីតាំង ៖ ទីស្នាក់ការកណ្តាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី
- កម្មវិធីបង្ហាញព័ត៌មានលម្អិត (Roadshow) លើកទី២
  - កាលបរិច្ឆេទ ៖ ១០ មីនា ២០២០ ចាប់ពីម៉ោង ២:០០រសៀល ដល់ ០៤:៣០រសៀល
  - ទីតាំង ៖ ទីស្នាក់ការកណ្តាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

### ៣.៦.៣. ការបរិច្ឆេទប៊ុកបៀលឌីង ទីតាំង និងនីតិវិធី

**កាលបរិច្ឆេទ** ៖ ៣ មីនា ដល់ ១៤ មីនា ២០២០ (ម៉ោង៨:០០ព្រឹក ដល់ម៉ោង ៥:០០ ល្ងាច ពីថ្ងៃចន្ទ ដល់ ថ្ងៃសៅរ៍)

**ទីតាំង** ៖ ទីស្នាក់ការភ្នាក់ងារចែកចាយលក់

- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី (ACS) និង បញ្ជរនៅតាមសាខារបស់ធនាគារ អេស៊ីលីដា ក្នុងរាជធានីភ្នំពេញ សាខាទីរួមខេត្តសៀមរាប ក្រុងព្រះសីហនុ សាខាទីរួមខេត្តបាត់ដំបង សាខាទីរួមខេត្តកំពង់ចាម សាខាទីរួមខេត្តកំពត សាខាទីរួមខេត្តស្វាយរៀង និង សាខាទីរួមខេត្តបន្ទាយមានជ័យ
- យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី
- អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី (SBI)
- អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក (RHBS)
- កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (CAMPUSEC)
- ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (PPS)
- កាណា ស៊ីឃ្យូរីធី អិលធីឌី (CNS)

**នីតិវិធី**

- វិនិយោគិនត្រូវមានគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក.។
- វិនិយោគិនត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុកបៀលឌីងនៅទីតាំងរបស់ភ្នាក់ងារចែកចាយ។

- វិនិយោគិនត្រូវដាក់តម្កល់ប្រាក់ចំនួន ១០% នៃតម្លៃសរុបនៃមូលបត្រដែលមានបំណងចង់ធ្វើបរិវិសកម្ម ទៅក្នុងគណនីប៊ុកបៀលឌីងរបស់ធនាគារ អេស៊ីលីដា នៅធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

**ឈ្មោះគណនី** ៖ ធនាគារ អេស៊ីលីដា ភីអិលស៊ី - គណនីប៊ុកបៀលឌីង

**លេខគណនី** ៖ 0001-03571769-1-4 (ខ្មែររៀល)

Swift Code ៖ ACLBKHPP[30]

### ៣.៦.៤. លទ្ធផលនៃការធ្វើប៊ុកបៀលឌីង

បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានមានប្រសាសន៍ថា "វិនិយោគិនរូបវន្តបុគ្គល ជាង ២.០០០នាក់ បានចូលរួមនៅក្នុងដំណើរការកំណត់ថ្លៃភាគហ៊ុន (ប៊ុកបៀលឌីង) របស់ធនាគារ។ នេះគឺជាជោគជ័យមួយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត និងជាធនាគារពាណិជ្ជទីមួយ ដែលនឹងចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ នៅពេលដែល វិនិយោគិនរូបវន្តបុគ្គលក្លាយជាភាគហ៊ុនិករបស់ធនាគារ រឹតតែធ្វើឲ្យយើងបង្កើនទំនាក់ទំនងយ៉ាងជិតស្និត និងកាន់តែរឹងមាំថែមទៀតជាមួយនឹងអតិថិជន ប្រកបដោយវិសាលភាពទូលំទូលាយ។ យើងខ្ញុំសូមថ្លែងអំណរគុណ ដល់វិនិយោគិនសក្ដានុពលរបស់ធនាគារទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងដំណើរការកំណត់ថ្លៃភាគហ៊ុន (ប៊ុកបៀលឌីង) និងទិញភាគហ៊ុនរបស់ធនាគារ"។

លោក Han Kyung Tae អគ្គនាយក ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី បានមានប្រសាសន៍ថា "ទោះបីជាមានកង្វល់អំពីជំងឺ Covid-19 និងការកើនឡើងនៃភាពមិនប្រាកដនៅលើទីផ្សារហិរញ្ញវត្ថុសកលក៏ដោយ ក៏តម្រូវការចូលរួមដាក់សំណើទិញ និងកំណត់ថ្លៃភាគហ៊ុន (ប៊ុកបៀលឌីង) មានចំនួនច្រើនគួរឲ្យកត់សម្គាល់ ដោយតម្រូវការសរុបមានចំនួន ៣ដង លើសចំនួនភាគហ៊ុនដែលបានបម្រុងទុកក្នុងដំណាក់កាលប៊ុកបៀលឌីង។ លទ្ធផលនៃការកំណត់ថ្លៃភាគហ៊ុន (ប៊ុកបៀលឌីង) នាពេលនេះ ជាលទ្ធផលបណ្ដោះអាសន្ននៅឡើយ ហើយនឹងត្រូវដាក់ជូនក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ("ផ.ម.ក.") និង គណៈកម្មការមូលបត្រកម្ពុជា ("គ.ម.ក.") ដើម្បីអនុម័តលើថ្លៃចុងក្រោយ។ ការជូនដំណឹងខាងលើនេះ គឺក្នុងគោលបំណងជូនព័ត៌មានខ្លះៗជាមុនដល់វិនិយោគិន ដើម្បីអនុញ្ញាតឲ្យវិនិយោគិនរៀបចំខ្លួន និងត្រៀមខ្លួនចូលរួមដំណាក់កាលបរិវិសកម្ម ដែលគ្រោងនឹងចាប់ផ្ដើម នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ខាងមុខនេះ។ ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ធនាគារនេះ គឺជាឱកាសមាស របស់វិនិយោគិនរូបវន្តបុគ្គល

---

30 ធនាគារអេស៊ីលីដា, សេចក្ដីជូនដំណឹងអំពីដំណើរការកំណត់ថ្លៃភាគហ៊ុន (ប៊ុកបៀលឌីង), https://www.acledabank.com.kh/kh/khm/listing-bookbuilding, (ចូលទស្សនាថ្ងៃទី ០៦ សីហា ២០២០)

ដើម្បីក្លាយជាភាគហ៊ុនិករបស់ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្តបំផុត និងជាធនាគារមានស្ថានភាពហិរញ្ញវត្ថុរឹងមាំបំផុតនៅក្នុងព្រះ-រាជាណាចក្រកម្ពុជា"។ លោក Han Kyung Tae បានបន្ថែមទៀតថា "ភាគ-ហ៊ុនចំនួន ៤.៣៧៥.៦៩៦ ត្រូវបានបម្រុងទុកសម្រាប់វិនិយោគិនដែលបានជោគជ័យនៅក្នុងដំណាក់កាលកំណត់ថ្លៃភាគហ៊ុន (ប៊ុកបៀលឌីង)។ [...] វិនិយោគិនដែលទទួលបានជោគជ័យ និងវិនិយោគិនដែលមិនទទួលបានជោគជ័យ នៅតែអាចទិញភាគ-ហ៊ុនរបស់ធនាគារបន្ថែមទៀតបាននៅក្នុងដំណាក់កាលបរិវិសកម្ម។ នៅក្នុងដំណាក់កាលបរិវិសកម្ម មានភាគ-ហ៊ុនសរុបរហូតដល់ ២១.៨៧៨.៤៧៧ ភាគហ៊ុន សម្រាប់ដាក់លក់ជូនវិនិយោគគិនសាធារណៈ នៅក្នុងតម្លៃចុងក្រោយ"។[31]

## ៣.៧. ដំណើរការធ្វើបរិវិសកម្ម ( Subscription )

ដំណើរការបរិវិសកម្មគឺជាដំណើរការសុំចុះឈ្មោះទិញមូលបត្រនៅពេលក្រុមហ៊ុនធ្វើសំណើលក់ជាសាធារណៈ។ វិនិយោគិនដែលទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង អាចដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មលើសពីចំនួនដែលបានធ្វើប៊ុកបៀលឌី ឯវិនិយោគដែលពុំទទួលបានជោគជ័យ ឬមិនបានចូលរួមក្នុងដំណាក់កាលប៊ុកបៀលឌីងនៅតែអាចដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មបាន។

ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបញ្ចប់ដំណើរការបរិវិសកម្ម កាលពីថ្ងៃសុក្រ ទី២៤ ខែមេសា ឆ្នាំ ២០២០ ។ ធនាគារបានទទួលការអនុម័តពី គណៈកម្មការមូលបត្រកម្ពុជា លើលទ្ធផលនៃការធ្វើ បរិវិសកម្ម នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ។ (ទម្រង់លិខិតសូមចូលរួមធ្វើបរិវិសកម្មមានក្នុងឧបសម្ព័ន្ធ ៣ និង លទ្ធផលនៃការធ្វើបរិវិសម្ព័ន្ធមានក្នុងឧបសម្ព័ន្ធ ៤)

បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រសាសន៍ថា "ទោះបីជាមានផលប៉ះពាល់យ៉ាងខ្លាំងជាសកល ពីការរីករាលដាលនៃវីរុសកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏វិនិយោគិនប្រមាណ ២,៤៩៧ នាក់ បានចូលរួមក្នុងដំណើរការបរិវិសកម្ម ដោយចំណាយពេលវេលាដ៏មានតម្លៃ និងថវិកា ដើម្បីវិនិយោគនៅក្នុង ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ ការចូលរួមយ៉ាងសកម្មនេះ ស្តែងចេញពីការជឿទុកចិត្តរបស់សាធារណជន ចំពោះលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដ៏រឹងមាំ ក៏ដូចជាការឈានមុខគេរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងវិស័យធនាគារនៅកម្ពុជា ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រនេះ និងសូមថ្លែងអំណរគុណដល់អតិថិជន និងវិនិយោគិនទាំងអស់ ដែលបានវិនិយោគក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារ។ លោកបានបន្ថែមថា "ធនាគារ អេស៊ី-

31 ធនាគារអេស៊ីលីដា, លទ្ធផលដ៏គាប់ប្រសើរនៃដំណើរការកំណត់ថ្លៃភាគហ៊ុន (ប៊ុកបៀលឌីង) របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី, https://www.acledabank.com.kh/kh/khm/md_ln20200317, (ចូលទស្សនាថ្ងៃទី ០៦ សីហា ២០២០)

លីដា ភីអិលស៊ី គ្រោងនឹងចុះបញ្ជីភាគហ៊ុនជាផ្លូវការនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នៅក្នុងខែឧសភា ឆ្នាំ២០២០។ បន្ទាប់ពីការចុះបញ្ជីនេះត្រូវបានបញ្ចប់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងក្លាយជាធនាគារពាណិជ្ជដំបូងគេ ដែលមានការជួញដូរភាគហ៊ុនជាសាធារណៈនៅកម្ពុជា"។

លោក Han Kyung Tae អគ្គនាយកក្រុមហ៊ុន យាន់តា ស៊ីឃ្យួរីធី (ខេមបូឌា) ភីអិលស៊ី បានមានប្រសាសន៍ថា "ទោះបីជាស្ថិតនៅក្នុងកំឡុងពេលនៃការរីករាលដាលនៃវីរុសកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានលទ្ធផលល្អ។ ធនាគារ និងគណៈគ្រប់គ្រងធនាគារ បានបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ ក្នុងការជម្រុញការចុះបញ្ជី ទៅតាមផែនការដែលបានគ្រោងទុក ហើយការប្តេជ្ញាចិត្តនេះហាក់ដូចជាការសម្រេចចិត្តដ៏ប្រយ័ត្នប្រយែងមួយ។ ក្នុងនាមជាក្រុមហ៊ុនធានាទិញមូលបត្រដែលដឹកនាំគម្រោងដ៏សំខាន់នេះ ក្រុមហ៊ុន យាន់តា ស៊ីឃ្យួរីធី (ខេមបូឌា) នឹងបន្តធ្វើឲ្យអស់ពីសមត្ថភាព ដើម្បីជួយទាំងក្រុមហ៊ុនបោះផ្សាយ និងទាំងវិនិយោគិនយ៉ាងច្រើន ដែលបានចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនេះ ដោយផ្តោតលើការបង្កើនសន្ទនីយភាពដល់ភាគហ៊ុនរបស់ធនាគារនៅក្នុងទីផ្សារបន្ទាប់ ។ យើងខ្ញុំជឿជាក់ថា ការជួយក្រុមហ៊ុនបោះផ្សាយក្នុងការធ្វើការបោះផ្សាយភាគហ៊ុនបន្តបន្ទាប់មកទៀត និងការរៀបចំវិធីសាស្រ្តជួញដូរតាមការចរចានាពេលអនាគត នឹងជួយបង្កើនសន្ទនីយភាព និងទាក់ទាញវិនិយោគិនបរទេសកាន់តែច្រើន មិនត្រឹមតែសម្រាប់ភាគហ៊ុនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះទេ ថែមទាំងសម្រាប់ទីផ្សារមូលធននៅកម្ពុជាផងដែរ"។[32]

## ៣.៨. ឥទ្ធិពលភាគហ៊ុនអេស៊ីលីដាក្នុងផ្សារមូលបត្រកម្ពុជា

### ៣.៨.១. ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅ ផ.ម.ក.

**តារាងទី១១៖** ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅផ.ម.ក.

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ឆ្នាំបង្កើត | ១៩៩៣ |
| ចំណាត់ថ្នាក់វិស័យ | ហិរញ្ញវត្ថុ |

32 ធនាគារអេស៊ីលីដា, សេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃការធ្វើបរិវិសកម្ម, https://www.acledabank.com.kh/kh/khm/listing-subscription-result, (ចូលទស្សនាថ្ងៃទី ០៦ សីហា ២០២០)

| | |
|---|---|
| ចំនួនភាគហ៊ុនចុះបញ្ជី | ៤៣៣,១៦៣,០១៩ |
| និមិត្តសញ្ញា | ធមក (ខ្មែរ) ABC (អង់គ្លេស) |
| គេហទំព័រ | www.acledabank.com.kh |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| លេខកូដស្តង់ដារ | KH1000100003 |
| កាលបរិច្ឆេទចុះបញ្ជី | ២៥ ឧសភា ២០២០ |
| ចំនួនបុគ្គលិក | ១២,១១៩ នាក់ |

### ៣.៨.២. **ការជួញដូរមូលបត្រកម្មសិទ្ធិ** ABC **នៅ ផ.ម.ក.**

**សប្តាហ៍ទី១**

**តារាងទី១២៖** ទិន្នន័យការជួញដូរ ABC សប្តាហ៍ទី១

| កាលបរិច្ឆេទ | ថ្លៃបិទ (រៀល) | ទំហំជួញដូរហ៊ុន | តម្លៃជួញដូរ ABC (រៀល) | តម្លៃជួញដូរសរុបនៅផមក |
|---|---|---|---|---|
| ២៥ ឧសភា ២០២០ | ១៦,៥០០ | ១៥,៨៨៨ | ២៥៨,៧៤៩,១៨០ | ២៦៩,៧០៨,០០០ |
| ២៦ ឧសភា ២០២០ | ១៧,៨៨០ | ៣២,២៤៦ | ៥៦០,៤៤៣,៧០០ | ៦៨០,១២៨,០០០ |
| ២៧ ឧសភា ២០២០ | ១៩,៦០០ | ២៥០,៩១០ | ៤,៨០៤,៩១៦,៨៤០ | ៥,១០៩,៤៨៨,០០០ |
| ២៨ ឧសភា ២០២០ | ២១,៥៥០ | ២៣៩,០៣០ | ៤,៩៣៦,៦៦៨,២០០ | ៥,១៦១,៣៦០,០០០ |
| ២៩ ឧសភា ២០២០ | ២២,៦០០ | ៧៩៣,១៥៩ | ១៨,២១៨,៦០៨,២៥០ | ១៨,៤៤២,៧៨០,០០០ |

*សន្មត់ ១ ដុល្លារ = ៤០០០ រៀល

ការជួញដូរភាគហ៊ុនរបស់ធនាគារ អេស៊ីលីដា នៅទីផ្សារមូលបត្រកម្ពុជាក្នុងទីផ្សារបន្ទាប់ពិតជាមានទំហំធំគួរអោយកត់សម្គាល់។ ជាក់ស្តែងជាមធ្យមនៅក្នុងសប្តាហ៍ថ្ងៃទី២៥-២៩ ឧសភា ២០២០ ទំហំជួញដូរ

ភាគហ៊ុន ABC មានប្រមាណ ៩៧% នៃការជួញដូរភាគហ៊ុនសរុបនៅផ្សារមូលបត្រកម្ពុជា។ នេះជាការបង្ហាញអំពីការមានទំនុកចិត្តខ្ពស់ពីសំណាក់អ្នកវិនិយោគទៅលើធនាគារមួយនេះ។

រឿងដែលគួរឲ្យចាប់អារម្មណ៍មួយទៀតនោះគឺ តម្លៃរបស់មូលបត្រ ABC ដែលបានកើនឡើងយ៉ាងគំហុក។ តួយ៉ាង តម្លៃ IPO របស់ ABC ស្មើនឹង ១៦,២០០រៀល បានកើនដល់ទៅ ២២,៦០០ រៀលក្នុងមួយភាគហ៊ុននៅថ្ងៃទី ២៩ ឧសភា ២០២០ ពោលគឺមានកំណើន ៦,៤០០រៀល ដែលប្រហាក់ប្រហែលនឹង ៣៩%។

**សប្តាហ៍ទី២**

**តារាងទី១៣៖** ទិន្នន័យការជួញដូរ ABC សប្តាហ៍ទី២

| កាលបរិច្ឆេទ | ថ្លៃបិទ (រៀល) | ទំហំជួញដូរហ៊ុន | តម្លៃជួញដូរ ABC (រៀល) | តម្លៃជួញដូរសរុបនៅផមក |
|---|---|---|---|---|
| ០១ មិថុនា ២០២០ | ២១,៧០០ | ២៦៦,៤២៩ | ៥,៩៣៦,៦៩៨,២០០ | ៦,០៣២,៣៦៤,០០០ |
| ០២ មិថុនា ២០២០ | ១៩,៥៦០ | ២៨៤,០៥១ | ៥,៦៩៨,១១៦,០៥០ | ៥,៧៣៧,៦១២,០០០ |
| ០៣ មិថុនា ២០២០ | ១៩,៦៨០ | ៣០៥,៥២៩ | ៥,៨៩៨,៣៣៤,៨២០ | ៥,៩៩១,៧៩៦,០០០ |
| ០៤ មិថុនា ២០២០ | ១៩,៨៤០ | ៦៨,១៦៦ | ១,៣៥១,១៤៤,១៨០ | ១,៤៣៨,០៥៦,០០០ |
| ០៥ មិថុនា ២០២០ | ១៩,៨៤០ | ៤០,៧៨១ | ៨០៧,៩២៦,២០០ | ៩០០,៦៨០,០០០ |

*សន្មត់ ១ ដុល្លារ = ៤000 រៀល

បន្ទាប់ពីមានកំណើនថ្លៃយ៉ាងគំហុកនៅសប្តាហ៍ទី ១ នៃការធ្វើចរាចរណ៍ជួញដូរក្នុងផ្សារមូលបត្រកម្ពុជា ABC បានបង្ហាញការសញ្ញាធ្លាក់ចុះ ទាំងតម្លៃ និងទំហំជួញដូរ ដោយក្នុងសប្តាហ៍ ០១-០៥ ឧសភា ២០២០ នេះ ABC មានតម្លៃជាមធ្យម ២០,១២៤ រៀល/មូលបត្រ។ ទោះបីជាយ៉ាងនេះក្តី តម្លៃរបស់មូលបត្រនេះនៅតែមានភាពទាក់ទាញក្នុងចំណោមអ្នកវិនិយោគ។

ទោះជាតម្លៃរបស់មូលបត្រនេះមានការថមថយក្តី ក៏ទំហំនៃការជួញដូរមូលបត្រ ABC បន្តមានភាពលេចធ្លោ ដោយសារតែជាង ៩៨% នៃមូលបត្រកម្មសិទ្ធិទាំងអស់ដែលមានចរាចរណ៍ជួញដូរក្នុងផ្សារមូលបត្រកម្ពុជា ជាមូលបត្រ ABC ។

**សប្តាហ៍ទី៣**

**តារាងទី១៤៖** ទិន្នន័យការជួញដូរ ABC សប្តាហ៍ទី៣

| កាលបរិច្ឆេទ | ថ្លៃបិទ (រៀល) | ទំហំជួញដូរហ៊ុន | តម្លៃជួញដូរ ABC (រៀល) | តម្លៃជួញដូរសរុបនៅផមក |
|---|---|---|---|---|
| ០៨ មិថុនា ២០២០ | ១៩,៣៨០ | ១០៨,៨៤៩ | ២,១១៦,៦៦១,០៨០ | ២,៣០០,៦២៨,០០០ |
| ០៩ មិថុនា ២០២០ | ១៩,៣៤០ | ៣៦,៨៣១ | ៧១២,០២៧,៥០០ | ៧៨៨,៤៧៦,០០០ |
| ១០ មិថុនា ២០២០ | ១៩,៣៤០ | ១២,៩៤០ | ២៥០,៤៩១,៤២០ | ៦០៨,៧០៨,០០០ |
| ១១ មិថុនា ២០២០ | ១៩,៤០០ | ៣១,៥៧៤ | ៦១០,៨១៩,១២០ | ៧១៣,១៣២,០០០ |
| ១២ មិថុនា ២០២០ | ១៩,២៨០ | ២៨,៨៥៤ | ៥៥៧,១០៣,៧២០ | ៦០០,០៦០,០០០ |

*សន្មត់ ១ ដុល្លារ = ៤០០០ រៀល

តាមរយៈតារាងខាងលើនេះ ABC បន្តធ្លាក់ចុះនូវតម្លៃបន្តិចបន្តួច ដោយក្នុងសប្តាហ៍ ០៨-១២ មិថុនា ២០២០នេះ វាមានតម្លៃជាមធ្យម ១៩,៣៤៨ រៀល/មូលបត្រ។ ទំហំជួញដូរមូលបត្រ ABC នៅតែរក្សាការមានប្រៀបលើមូលបត្រដទៃទៀត ដោយរក្សាបាន ៨៤.៧% នៃទំហំការជួញដូរមូលបត្រសរុបនៅក្នុងផ្សារមូលបត្រកម្ពុជា។

**សប្តាហ៍ទី៤**

**តារាងទី១៥៖** ទិន្នន័យការជួញដូរ ABC សប្តាហ៍ទី៤

| កាលបរិច្ឆេទ | ថ្លៃបិទ (រៀល) | ទំហំជួញដូរហ៊ុន | តម្លៃជួញដូរ ABC (រៀល) | តម្លៃជួញដូរសរុបនៅផមក |
|---|---|---|---|---|
| ១៥ មិថុនា ២០២០ | ១៨,៨៦០ | ៨០,០១៦ | ១,៥១៦,០៨០,៦៦០ | ១,៥៧០,៦៨០,០០០ |
| ១៦ មិថុនា ២០២០ | ១៨,៦២០ | ៧២,៩០៤ | ១,៣៦១,០១០,៤២០ | ១,៤៦២,៦២០,០០០ |
| ១៧ មិថុនា ២០២០ | ១៨២៦០ | ៧៩,៥៥៤ | ១,៤៥១,២២១,៨០០ | ១,៥៥០,០២០,០០០ |
| ១៨ មិថុនា ២០២០ | ថ្ងៃសម្រាក ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចយាយ | | | |

| | | | | |
|---|---|---|---|---|
| ១៩ មិថុនា ២០២០ | ១៨,១០០ | ៤២,៨១៣ | ៧៧៤,៩៩៦,០៨០[33] | ៨០៦,៣២៤,០០០[34] |

*សន្មត់ ១ ដុល្លារ = ៤000 រៀល

គេសង្កេតឃើញថា មូលបត្រ ABC បន្តការធ្លាក់ចុះតម្លៃរបស់ខ្លួន ក៏ប៉ុន្តែតម្លៃជាមធ្យមរបស់ ABC នៅសប្តាហ៍ ១៥-១៩ មិថុនា ២០២០ ស្មើនឹង ១៨,៤៦០ រៀល/មូលបត្រ នៅតែមានតម្លៃខ្ពស់ជាង IPO (១៦,២០០ រៀល)។ ប្រការនេះបានន័យថា អ្នកវិនិយោគជាមួយ ABC តាំងតែពីដំបូងនៅតែមានផលចំណេញជាសាច់ប្រាក់ (Capital Gain) ដដែល។ ម្យ៉ាងវិញទៀត ABC មាន Liquidity ខ្ពស់ព្រោះថា ទំហំជួញដូរ ៩៤.៦% ក្នុងផ្សារមូលបត្រកម្ពុជា ជាមូលបត្ររបស់ធនាគារ អេស៊ីលីដា។

33 ផ្សារមូលបត្រកម្ពុជា, ទិន្នន័យទីផ្សារ-មូលបត្រកម្មសិទ្ធិ-ថ្លៃមូលបត្រ, http://csx.com.kh/data/stock/daily.do?MNCD=60202, (ចូលទស្សនាថ្ងៃ ១០ សីហា ២០២០)

34 ទំព័រហ្វេកប៊ុកផ្សារមូលបត្រកម្ពុជា, ព័ត៌មានទីផ្សារប្រចាំសប្តាហ៍, https://web.facebook.com/cambodia.csx/photos/a.676025919146092/3102493739832619/, (ចូលទស្សនាថ្ងៃ ១០ សីហា ២០២០)

# សេចក្ដីសន្និដ្ឋាន

# និង

# អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវទាក់ទងនឹងប្រធានបទ **ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ធនាគារ អេស៊ីលីដា** ខ្ញុំបាទទទួលបានចំណេះដឹងជាច្រើន ពិសេសពុទ្ធិដែលទាក់ទងនឹង ដំណើរការ និងនីតិវិធី ដែលក្រុមហ៊ុនមួយត្រូវតែគោរពប្រតិបត្តិដើម្បីទទួលបានសិទ្ធិក្នុងការចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជាដើម្បីក្លាយជាក្រុមហ៊ុនសាជីវកម្ម។ នីតិវិធីទាំងនេះគឺមានលក្ខណៈស្មុគស្មាញបន្តិច ប៉ុន្តែវាមិនពិបាកដល់កម្រិតដែលធ្វើអោយក្រុមហ៊ុនមានការរារែកក្នុងការសម្រេចចិត្តចុះបញ្ជីជាមួយផ្សារមូលបត្រកម្ពុជានេះដែរ។ លើសពីនេះទៀតដំណើរការ និងនីតិវិធីទាំងនេះធ្វើឡើង ដើម្បីធានាឲ្យមានតម្លាភាពសម្រាប់វិនិយោគិនដែលមានបំណងចង់វិនិយោគក្នុងផ្សារមូលបត្រ ពោលគឺដើម្បីការពារផលប្រយោជន៍អ្នកវិនិយោគ ក្នុងការជ្រើសរើសក្រុមហ៊ុនដើម្បីធ្វើការដាក់ទុនជាមួយ។

